មេរៀនទី ១

# ព្រះជាម្ចាស់៖ និស្ស័យ និង លក្ខណសម្បត្តិធម្មជាតិរបស់ទ្រង់

ជាការឆ្លើយតបទៅនឹងសំណួរដ៏ចំណាស់មួយដែលសួរថា "តើអ្នកអាចស្វែងយល់ជំរៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ឬស្គាល់លក្ខណៈដ៏ប្រសើរឥតខ្ចោះនៃព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុតបានឬទេ?" (គម្ពីរយ៉ូប ១១:៧) យើងសូមឆ្លើយថា "ទេ"! បញ្ហាដ៏ធំដែលយើងប្រឈមមុខនៅក្នុងការខឹតខំប្រឹងប្រែងស្វែងយល់ពីព្រះជាម្ចាស់ គឺថាមនុស្សជាតិដែលនៅមានដែនកំណត់ មិនអាចយល់ពីភាពគ្មានដែនកំណត់បាននោះទេ!

ក្រៅពីការបើកបង្ហាញដែលយើងមាន ទាក់ទងអំពីនិស្ស័យ និង លក្ខណសម្បត្តិ ឬ គុណលក្ខណៈរបស់ព្រះជាម្ចាស់ យើងគ្មានមធ្យោបាយណាផ្សេង ដើម្បីដឹងពីភាពជាព្រះជាម្ចាស់បានឡើយ។ យើងអាចយល់ដឹងខ្លះៗ អំពីភាពជាព្រះរបស់ព្រះអង្គបានតែនៅពេលដែលទ្រង់បង្ហាញពីនិស្ស័យ និង លក្ខណសម្បត្តិរបស់ទ្រង់ ដោយអង្គទ្រង់ផ្ទាល់តែប៉ុណ្ណោះ។ ដូច្នេះ អ្វីដែលទ្រង់បើកបង្ហាញឲ្យយើងឃើញអំពីអង្គទ្រង់ គឺមានភាពសុក្រឹត ប៉ុន្តែគ្រាន់តែជាការបង្ហាញតែមួយផ្នែកនៃអត្ថិភាពរបស់ទ្រង់តែប៉ុណ្ណោះ។

យើងក៏អាចស្គាល់ព្រះជាម្ចាស់ នៅពេលដែលទ្រង់មានទំនាក់ទំនងជាមួយយើង។ យើងទទួលបានចំណេះដឹងអំពីទ្រង់តាមរយៈការសិក្សាពី និស្ស័យ និង លក្ខណសម្បត្តិរបស់ទ្រង់ ដ្បិតទាំងនេះបានបង្ហាញពីផ្នែកមួយនៃអត្ថិភាពរបស់ទ្រង់។ ដើម្បីទទួលបាននូវចំណេះដឹងដ៏គួរឲ្យទុកចិត្តបានទាំងស្រុងអំពីនិស្ស័យ និង លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ យើងត្រូវចាប់ផ្តើមពីការសិក្សាទៅលើការបើកបង្ហាញរបស់ព្រះជាម្ចាស់អំពីអង្គទ្រង់ ដែលមាននៅក្នុងព្រះគម្ពីរជាមុនសិន។ នៅពេលដែលយើងទទួលបានចំណេះដឹងទូទៅខ្លះៗអំពីព្រះជាម្ចាស់ ពីការសង្កេតមើលស្នាព្រះហស្តរបស់ទ្រង់នៅក្នុងធម្មជាតិហើយ យើងត្រូវងាកទៅរកព្រះបន្ទូលរបស់ទ្រង់ដើម្បីទទួលបាននូវការយល់ដឹង ពីនិស្ស័យ និងលក្ខណសម្បត្តិរបស់ទ្រង់។

នៅពេលអ្នកសិក្សាអំពីព្រះអាទិករនៃយើង សូមឲ្យអ្នកយល់ឃើញកាន់តែច្បាស់ថា ដោយសារតែទ្រង់យកព្រះទ័យទុកដាក់នឹងអ្នក ទើបនាំឲ្យមានការបើកបង្ហាញអង្គទ្រង់ កាន់តែច្រើនឡើង នៅទូទាំងសម័យកាលកន្លងមកនេះ។ ការបើកបង្ហាញដោយអង្គទ្រង់ផ្ទាល់នេះ បានឈានទៅដល់ភាពពេញលេញនៅពេលដែលទ្រង់បានមានព្រះបន្ទូលជាលើកចុងក្រោយ តាមរយៈព្រះបុត្រារបស់ទ្រង់។ (គម្ពីរហេប្រឺ ១:២)។

## គម្រោងមេរៀន

ក. និស្ស័យរបស់ព្រះជាម្ចាស់

ខ. គុណលក្ខណៈធម្មជាតិរបស់ព្រះជាម្ចាស់

## វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកនឹងអាចៈ

១. សរសេរអំពីគុណសម្បត្តិនៃបុគ្គលិកលក្ខណៈដែលព្រះជាម្ចាស់មាន។

២. បកស្រាយនិស្ស័យខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់។

៣. រៀបរាប់ និង កំណត់ន័យ ការរួបរួម និង ភាពតែមួយ របស់ព្រះជាម្ចាស់។

៤. បកស្រាយសេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរអំពីព្រះត្រៃឯក។

៥. បង្ហាញពីការជាប់ពាក់ព័ន្ធសម្រាប់គ្រិស្ដបរិស័ទទៅនឹងភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់។

៦. ប្រាប់អំពីអត្ថន័យនៃភាពមិនចេះប្រែប្រួលរបស់ព្រះជាម្ចាស់ សម្រាប់អ្នកទៅតាមការយល់ដឹង និង បទពិសោធន៍ជាគ្រិស្ដបរិស័ទរបស់អ្នក។

៧. សរសេរ និង កំណត់ន័យគុណលក្ខណៈរបស់ព្រះជាម្ចាស់។

## សកម្មភាពក្នុងការសិក្សា

១. អានសេចក្ដីណែនាំ និង វត្ថុបំណងនៃមុខវិជ្ជា ដោយយកចិត្តទុកដាក់។

២. សិក្សាគម្រោងមេរៀន និង វត្ថុបំណងមេរៀន។ ការទាំងនេះ នឹងជួយអ្នកឲ្យស្គាល់ពីអ្វីដែលអ្នកគួរដឹង នៅពេលដែលអ្នកសិក្សាមេរៀននេះ។

៣. អានមេរៀន និង ធ្វើលំហាត់ទៅតាមដំណើរវិវឌ្ឍរបស់មេរៀន។ ផ្ទៀងផ្ទាត់ចម្លើយរបស់អ្នកជាមួយ ចម្លើយដែលបានផ្ដល់ជូននៅចុងបញ្ចប់នៃមេរៀន។ វាជារឿងដ៏សំខាន់ណាស់ដែលអ្នកត្រូវស្វែងរក និង អានរាល់បទគម្ពីរដែលបានផ្ដល់ជូននៅក្នុងមេរៀន។

៤. ពាក្យជាច្រើននៅក្នុងមេរៀននេះ អាចជាពាក្យថ្មីសម្រាប់អ្នក។ មានពាក្យខ្លះត្រូវបានយកមករៀបរាប់ នៅខាងក្រោមនេះទុកជាពាក្យសំខាន់ៗ។ ពិនិត្យមើលអក្ខរានុក្រមនៅក្នុងចុងបញ្ចប់នៃសៀវភៅនេះ ដើម្បីមើលនិយមន័យពាក្យសំខាន់ណា ដែលអ្នកមិនទាន់យល់។ ក៏មានពាក្យជាច្រើនទៀត ត្រូវ បានបកស្រាយនៅក្នុងមេរៀនផងដែរ។ ចូរប្រើប្រាស់ វាចនានុក្រម ដើម្បីស្វែងរកនិយមន័យពាក្យ ផ្សេងទៀតដែលអ្នកមិនយល់។

៥. ធ្វើការប្រឡងផ្ទាល់ខ្លួននៅចុងបញ្ចប់នៃមេរៀននេះ ហើយផ្ទៀតផ្ទាត់ចម្លើយរបស់អ្នកដោយយកចិត្ត ទុកដាក់ ជាមួយនឹងចម្លើយដែលបានផ្ដល់ជូននៅផ្នែកខាងក្រោយនៃសៀវភៅមេរៀននេះ។ ចូររំឭក ផ្នែកណាដែលអ្នកបានធ្វើខុស។

# ពាក្យសំខាន់

| | | |
|---|---|---|
| គុណលក្ខណៈ | ខ្ជាប់ខ្ជួន | ភាពសាមញ្ញ |
| ដោយឡែក | ការសម្តែងបង្ហាញ | ព្រះមហាក្សត្រ |
| ភាពវិសេស | សម្ភារ | សារធាតុ |
| សមាសភាព | រូបធាតុ | ដែលមានសារៈសំខាន់ |
| អស់កល្បជានិច្ច | សញ្ញានុភាព | ព្រះត្រៃឯក |
| អរូប | សព្វត្ថិភាព | ភាពខុសប្លែកពីគេ |
| អមតៈ | សព្វញ្ញុតញាណ | ការរួបរួម |

# ក. និស្ស័យរបស់ព្រះជាម្ចាស់

នៅពេលដែលអ្នកវិទ្យាសាស្ត្រធ្វើការសិក្សាទៅលើសារធាតុផ្សំនៅក្នុងឈាម ពួកគេបានរកឃើញថា ឈាមបង្កើតមកពីសារធាតុផ្សេងៗគ្នា និង ភាគល្អិតដ៏តូចៗដែលមានតួនាទីខុសៗពីគ្នា នៅក្នុងការរក្សាជីវិត។ វត្ថុរាវដ៏ស្មុគស្មាញនេះ ត្រូវបានច្របាច់ទៅពាសពេញប្រព័ន្ធបំពង់ដ៏សាំញ៉ាំមួយ ទាំងថ្ងៃទាំងយប់ ដោយម៉ាស៊ីនមាំមួនមួយ (បេះដូង) ដែលចេះបង្អន់ឲ្យទន់បន្ទាប់ពីចលនាច្របាច់ម្តងៗ។ ឈាមគឺជាលំហូរជីវិតនៃរូបកាយ។ ឈាមដឹកនាំអុកស៊ីសែន និង អាហារទៅគ្រប់កន្លែងក្នុងខ្លួនប្រាណ វាប្រឆាំងនឹងមេរោគ ដែលអាចចូលមកក្នុងខ្លួនប្រាណ និងជួយខ្លួនប្រាណសំអាតកាកសំណល់។ ដើម្បីធ្វើការទាំងនេះបាន គឺទាមទារឲ្យមានការសហប្រតិបត្តិការរវាងសួត តម្រងនោម និង សរីរាង្គផ្សេងៗ បន្ថែមពីលើបេះដូងទៀត។

នេះគ្រាន់តែជាឧទាហរណ៍មួយនៅក្នុងចំណោមប្រព័ន្ធជីវសាស្ត្រជាច្រើនទៀត ដែលមានការរៀបចំយ៉ាងល្អ អនុញ្ញាតឲ្យជីវិតអាចកើតមានឡើងបាន។ ប្រាកដណាស់ ការនេះទាមទារឲ្យមានព្រះដែលមានអំណាច និង ប្រាជ្ញាញាណអស្ចារ្យ ដើម្បីធ្វើការទាំងនេះឲ្យកើតមានឡើងបាន។ តើយើងដឹងអ្វីខ្លះអំពីព្រះអង្គនេះ? ចូរយើងក្រឡេកទៅមើលពីសេចក្តីពិតខ្លះៗ ដែលយើងបានដឹងអំពីព្រះអាទិកររបស់យើង គឺព្រះជាម្ចាស់។

## ព្រះជាម្ចាស់គឺជាព្រះដែលមានភាពជាបុគ្គល

**វត្ថុបំណងទី១.** *សរសេរអំពីគុណសម្បត្តិនៃបុគ្គលិកលក្ខណៈ ដែលព្រះជាម្ចាស់មាន។*

តើអ្វីដែលអ្នកគិតថាជាផ្នែកសំខាន់ៗរបស់មនុស្ស? ដៃ? សម្លេង? ភ្នែក? ប្រសិនបើបុគ្គលម្នាក់បាត់បង់របស់ណាមួយក្នុងចំណោមរបស់ទាំងនេះ គាត់ក៏នៅតែជាបុគ្គលម្នាក់ដដែល។ យើងប្រហែលជាអាចយល់ឃើញដូចគ្នា ថា*មនុស្សម្នាក់* គឺជាអ្វីផ្សេង មិនមែនគ្រាន់តែជា*ខ្លួនប្រាណ* តែប៉ុណ្ណោះទេ។ មនុស្សម្នាក់មានសមត្ថភាព គិត ទទួលអារម្មណ៍ និង ធ្វើការសម្រេចចិត្ត។ បើទោះបីជាព្រះជាម្ចាស់គ្មានព្រះកាយក៏ដោយ ទ្រង់ក៏ពិតមានព្រះប្រាជ្ញាញាណ ព្រះតម្រិះ និង ទទួលអារម្មណ៍ និង មានហេតុផលដែរ។ ព្រះគម្ពីរបានបង្ហាញថា ទ្រង់ធ្វើការទាក់ទងជាមួយអ្នកដទៃ (គម្ពីរទំនុកតម្កើង ២៥:១៤) ហើយទ្រង់ទទួលបានឥទ្ធិពលពីការឆ្លើយតបរបស់ពួកគេមកកាន់ទ្រង់ផងដែរ (គម្ពីរអេសាយ ១:១៤) ។ ទ្រង់ព្រះតម្រិះ (គម្ពីរអេសាយ ៥៥:៨) ហើយទ្រង់ធ្វើការសម្រេចព្រះទ័យ (គម្ពីរលោកុប្បត្តិ ២:១៨)។ ការទាំងអស់នេះ ជាលក្ខណសម្បត្តិនៃភាពបុគ្គល ដូច្នេះព្រះជាម្ចាស់ជាព្រះដែលមានភាពជាបុគ្គល។

យើងអាចដឹងអ្វីម្យ៉ាងទៀត អំពីបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់បាន នៅពេលយើងពិចារណាអំពីបុគ្គលិកលក្ខណៈរបស់យើង ដោយសារតែយើងបានបង្កើតមក ឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់។ ប្រាកដណាស់ ការធ្វើបែបនេះមានដែនកំណត់របស់វា។ យើងមិនត្រូវចាត់ទុកបុគ្គលិកលក្ខណៈរបស់យើង ជាខ្នាតគំរូដែលយើងអាចយកទៅវាស់វែងបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់បាននោះទេ ដ្បិតបុគ្គលិកលក្ខណៈដើមដំបូង គឺឃើញមានតែនៅក្នុងព្រះជាម្ចាស់តែប៉ុណ្ណោះ មិនមែននៅក្នុងមនុស្សនោះទេ។ បុគ្គលិកលក្ខណៈរបស់យើង គឺគ្រាន់តែជាលំនាំមួយនៃរបស់ដើមតែប៉ុណ្ណោះ។ បុគ្គលិកលក្ខណៈរបស់យើងក៏មិនមែនដូចគ្នាបេះបិទ ជាមួយនឹងបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ដែរ ប៉ុន្តែបុគ្គលិកលក្ខណៈរបស់យើងមានផ្ទុកនូវលក្ខណៈដែលស្រដៀងនឹងបុគ្គលិកលក្ខណៈរបស់

ទ្រង់។ ដូច្នេះ អ្វីដែលមើលទៅមិនល្អឥតខ្ចោះនៅក្នុងបុគ្គលិកលក្ខណៈរបស់យើង គឺយើញមានរបស់ព្រះជាម្ចាស់ថាជាការល្អឥតខ្ចោះទៅវិញ។

ប្រសិនបើអ្នកមានទំនាក់ទំនងរាប់អានជាមួយមនុស្ស ដែលមិនអនុញ្ញាតឲ្យអ្នកដឹងថាគេមានអារម្មណ៍បែបណា មិនដែលចែករំលែកគំនិតរបស់គេជាមួយអ្នក និង មិនដែលបង្ហាញនូវការចាប់អារម្មណ៍មកលើអ្នក អ្នកអាចនិយាយបានថា គេគ្មានភាពជាបុគ្គលនោះទេ។ នោះក៏ដោយសារតែ គេមិនសម្ដែងលក្ខណសម្បត្តិនៃភាពបុគ្គលម្នាក់មកឲ្យអ្នកឃើញ។ ប៉ុន្តែព្រះជាម្ចាស់គឺមិនយ៉ាងដូច្នេះទេ ។ ទ្រង់គាប់ព្រះហឫទ័យនឹងអ្នក។ ទ្រង់មានអារម្មណ៍សម្រាប់មនុស្ស ហើយទ្រង់មានទំនាក់ទំនងជាមួយពួកគេ។ លើសពីនេះ ទ្រង់ធ្វើការសម្រេចព្រះទ័យដោយយល់ដល់ពួកគេផង។

មនុស្សជាច្រើននាក់ជឿថា ព្រះដ៏ខ្ពស់ឧត្ដម ដែលបានបង្កើតផែនដីមកនេះ ទ្រង់គង់នៅដាច់ឆ្ងាយពីរឿងរ៉ាវរបស់មនុស្ស ពួកគេជឿថាវិញ្ញាណរបស់បុព្វបុរស ឬ វិញ្ញាណរបស់ធម្មជាតិមានជាប់ទាក់ទងជាមួយមនុស្សពីមួយថ្ងៃទៅមួយថ្ងៃ ជាជាងព្រះជាម្ចាស់ទៅទៀត។ ពិតណាស់ ការនេះគឺជាការយល់ច្រឡំមួយ។ ព្រះជាម្ចាស់ ទ្រង់យកព្រះហឫទ័យទុកដាក់ចំពោះរឿងរ៉ាវរបស់មនុស្សណាស់ ហើយទ្រង់ពិតជាទាក់ទងជាមួយយើងរាល់គ្នាដោយផ្ទាល់តែម្ដង។

## *លំហាត់អនុវត្តន៍*

១ តើមនុស្សនៅក្នុងសហគមន៍របស់អ្នក មានការយល់ឃើញពីព្រះជាម្ចាស់យ៉ាងដូចម្ដេចដែរ?

..................................................................................................................................

...............................................................................................................................

២ ប្រសិនបើព្រះជាម្ចាស់គឺជាបុគ្គលមួយរូប តើអ្នកគិតថា អ្នកអាចស្គាល់ទ្រង់ បែបផ្ទាល់ខ្លួនបានដោយរបៀបណា? ចូរប្រើសៀវភៅកត់ត្រារបស់អ្នកដើម្បីសរសេរចម្លើយនេះ។

៣ (ចូរជ្រើសរើសឃ្លាបំពេញត្រឹមត្រូវ)។ លក្ខណៈរបស់ព្រះជាម្ចាស់ដែលសម្ដែងឲ្យឃើញពីលក្ខណៈជាបុគ្គលរបស់ទ្រង់ គឺ

ក) រូបកាយ សង្គមធម៌ និង គុណលក្ខណៈខាងវិញ្ញាណរបស់ទ្រង់។

ខ) សមត្ថភាពក្នុងការធ្វើព្រះតម្រិះ ទទួលអារម្មណ៍ និង ធ្វើការសម្រេចព្រះទ័យរបស់ទ្រង់។

គ) សមត្ថភាពដែលអាចឲ្យគេចូលទៅរកបាន ឲ្យគេអាចឃើញ និងយល់បានពេញរបស់ទ្រង់។

# ព្រះជាម្ចាស់ជាវិញ្ញាណ

**វត្ថុបំណងទី២.** *បកស្រាយនិស្ស័យខាងវិញ្ញាណរបស់ព្រះជាម្ចាស់។*

តើអ្នកគិតយ៉ាងដូចម្ដេច នៅពេលដែលអ្នកបិទភ្នែករបស់អ្នក ហើយព្យាយាមនឹងស្រមៃពីរូបភាពរបស់ព្រះជាម្ចាស់? ប្រសិនបើអ្នកគិតឃើញរូបភាពណាមួយសម្រាប់ព្រះជាម្ចាស់នៅក្នុងគំនិតរបស់អ្នក នោះការគិតរបស់អ្នកគិតមិនដូចជាអ្វីដែលបទគម្ពីរបានបង្រៀននោះទេ។ ព្រះជាម្ចាស់គ្មានទម្រង់អ្វីសោះ

ឡើយ ព្រោះទ្រង់គឺជា*វិញ្ញាណ* (គម្ពីរយ៉ូហាន ៤:២៤) ហើយវិញ្ញាណគឺមិនអាចមើលឃើញនោះទេ។ គម្ពីរយ៉ូហាន១:១៨ ប្រាប់ពួកយើងថា "បកស្រាយនិស្ស័យខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់។"

*ព្រះជាម្ចាស់ជាវិញ្ញាណ!* នេះគឺជាពាក្យដែលយើងមានប្រយោគមួយប្រាប់យើងថាអ្វីជាព្រះជាម្ចាស់។ ដើម្បីយល់ប្រយោគនេះ យើងត្រូវគិតថា តើជា*វិញ្ញាណ* មានន័យយ៉ាងណា។ តើ*លក្ខណៈខាងឯវិញ្ញាណ* ឬ គុណសម្បត្តិដែលមានភាពជាវិញ្ញាណមានទាក់ទងទៅនឹងអ្វីខ្លះ? នេះមិនមែនជាគោលគំនិតដែលងាយស្រួលបកស្រាយនោះទេ ។ដូចដែលយើងបាននិយាយខាងលើ ព្រះគម្ពីរបានផ្តល់ឲ្យយើងបានឃើញពីការបើកបង្ហាញពីនិស្ស័យរបស់ព្រះជាម្ចាស់តែ*មួយចំណែក* តែប៉ុណ្ណោះ។ នៅពេលដែលយើងខិតខំប្រឹងប្រែងរៀបរាប់អំពីនិស្ស័យខាងឯវិញ្ញាណរបស់ទ្រង់ យើងប្រហែលជាប្រើពាក្យដែលថ្មីសម្រាប់អ្នក។ យើងនឹងព្យាយាម ផ្តល់និយមន័យសម្រាប់ពាក្យនីមួយៗ ពេលណាដែលយើងឃើញពាក្យទាំងនោះ។

១. ដំបូង ការស្រាវជ្រាវរបស់យើង នៅក្នុងបទគម្ពីរបង្ហាញឲ្យឃើញថា ព្រះជាម្ចាស់មានលក្ខណៈពិសេស និង មានសារៈសំខាន់ខុសប្លែកពីអ្វីដែលមាននៅក្នុងលោកីយ៍ (គម្ពីរអេភេសូ ៤:៦ គម្ពីរកូឡុស ១:១៥-១៧)។

ការមានលក្ខណៈ*ពិសេស* មានន័យថាមានតែមួយគត់។ ការមាន*សារៈសំខាន់* មានន័យថា មាន*សារធាតុ* ឬ មាន*លក្ខណៈសំខាន់* មាន*សមាសភាព។* ពាក្យថា*សារធាតុ* និង *សមាសភាព* មានន័យស្រដៀងគ្នា នៅពេលណាដែលប្រើសំរាប់ព្រះជាម្ចាស់។ ពាក្យទាំងនេះ សំដៅទៅលើគុណសម្បត្តិ និងគុណលក្ខណៈដែលបង្កើតបានជានិស្ស័យរបស់ទ្រង់ ហើយក៏ជាមូលដ្ឋានគ្រឹះនៃការបើកសម្តែងមកខាងក្រៅទាំងអស់របស់ទ្រង់។

២. ព្រះជាម្ចាស់ដែលមានសារៈសំខាន់នេះ គឺ*មិនអាចមើលឃើញ អរូប និង មិនផ្សំឡើងដោយផ្នែកណាមួយឡើយ។*

យើងបាននិយាយរួចម្តងហើយថា ព្រះជាម្ចាស់មានសារធាតុ ប៉ុន្តែទ្រង់មិនមែនជាសារធាតុដែលមាន*រូប* នោះទេ បានន័យថាទ្រង់មិនផ្សំឡើងពីរូបធាតុដូចយើងនោះទេ។ ព្រះជាម្ចាស់ជាសារធាតុ*ខាងឯវិញ្ញាណ* ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា "ខ្មោចគ្មានសាច់ គ្មានឆ្អឹង ដូចខ្ញុំទេ" (គម្ពីរលូកា ២៤:៣៩) ។ ដោយហេតុថា ព្រះជាម្ចាស់គឺជាវិញ្ញាណដែលមានន័យបរិសុទ្ធបំផុត ពេលលើកជាពាក្យទ្រង់មិនមានដែនកំណត់ដែលអាចគិតដល់ នៅពេលដែលអ្នកគិតអំពីមនុស្សនោះទេ។ ទ្រង់មិនមានសម្បត្តិ ឬ លក្ខណសម្បត្តិដែលមាននៅក្នុងរូបធាតុនោះទេ។ លោកប៉ូលរៀបរាប់ថាទ្រង់ជា "ព្រះមហាក្សត្រដែលគង់នៅអស់កល្បជានិច្ច ជាព្រះជាម្ចាស់តែមួយ ព្រះអង្គមានព្រះជន្មមិនចេះសាបសូន្យដែលមនុស្សមើលពុំឃើញ (គម្ពីរ១ធីម៉ូថេ ១:១៧) និងជា "ព្រះអង្គជាព្រះមហាក្សត្រធំលើសមហាក្សត្រនានាជាព្រះអម្ចាស់ធំលើសអម្ចាស់នានា មានតែព្រះអង្គមួយគត់ដែលមានព្រះជន្មអមតៈ ព្រះអង្គគង់នៅក្នុងពន្លឺ ដែលគ្មាននរណា អាចចូលជិតបានឡើយ ហើយក៏គ្មានមនុស្សណាបានឃើញ និងអាចឃើញព្រះអង្គបានដែរ" (គម្ពីរ១ធីម៉ូថេ ៦:១៥-១៦)។

ប្រសិនបើព្រះជាម្ចាស់ពិតជាវិញ្ញាណ ហើយមិនអាចមើលឃើញមែន តើយើងយល់យ៉ាងដូចម្តេចអំពីហេតុការណ៍នៅក្នុងព្រះគម្ពីរ ដូចជាហេតុការណ៍មួយដែលបានរៀបរាប់នៅក្នុងគម្ពីរ និក្ខមនំ ៣៣:១៩-

២៣ ដែលបានប្រាប់យើងថា លោកម៉ូសេបានឃើញព្រះជាម្ចាស់? រឿងនេះមិនមែនជាការប្រឆាំងនឹងការពិតដែលថាព្រះជាម្ចាស់ ជាព្រះដែលមិនអាចមើលឃើញ និង អរូបនោះឡើយ។ នៅហេតុការណ៍ខ្លះមនុស្សគ្រាន់បានឃើញពីរូបភាពឆ្លុះបញ្ចាំងនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ ប៉ុន្តែពួកគេមិនបានឃើញពីសមាសភាពរបស់ទ្រង់នោះទេ។ ហេតុការណ៍ផ្សេងទៀត បានបង្ហាញថា វិញ្ញាណអាចបង្ហាញរូបជាទម្រង់ដែលអាចមើលឃើញ។ ព្រះជាម្ចាស់អាចបង្ហាញអង្គទ្រង់តាម
រយៈការបង្ហាញព្រះកាយជារូបយ៉ាងល្អឥតខ្ចោះ។ ការនេះបានកើតឡើង នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកសណ្ឋិតលើព្រះយេស៊ូ ក្រោមទម្រង់ជាសត្វព្រាប នៅពេលព្រះយេស៊ូបានជ្រមុជទឹកហើយ (គម្ពីរយ៉ូហាន ១:៣២-៣៤)។ នៅពេលលោកយ៉ូហានបាទីស្ដបានឃើញទីសំគាល់នេះ លោកក៏បានជឿថាព្រះយេស៊ូគឺពិតជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់មែន។ ព្រះវិញ្ញាណដែលជារបស់ព្រះជាម្ចាស់ដែលមិនអាចមើលឃើញ បានបង្ហាញអង្គទ្រង់ក្នុងទម្រង់ជាសត្វព្រាប ដើម្បីឲ្យលោកយ៉ូហានអាចដឹងយ៉ាងប្រាកដពីអត្តសញ្ញាណរបស់ព្រះយេស៊ូ ដែលនឹងបានជ្រមុជយើងជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងឧទាហរណ៍ក្នុងគម្ពីរនិក្ខមនំជំពូក៣៣ លោកម៉ូសេក៏ត្រូវការការអះអាងពីព្រះជាម្ចាស់ ដើម្បីឲ្យលោកប្រឈមមុខនឹងកិច្ចការជាអ្នកដឹកនាំ ដែលព្រះជាម្ចាស់បានប្រទានមកសម្រាប់លោក ដូច្នេះ ព្រះជាម្ចាស់បានប្រទានឲ្យលោកបានឃើញពីទីសំគាល់មានរូបនោះ។

អ្នកប្រហែលជាកំពុងគិតថា "ប្រសិនបើព្រះជាម្ចាស់ទ្រង់អរូប ហេតុអ្វីបានជាព្រះគម្ពីរថ្លែងពីព្រះហស្ដ ព្រះបាទា ព្រះកាណ៌ ព្រះឱស្ឋ ព្រះនាសា ឬ ព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ដែរ? ហេតុអ្វីបានជាមានបទគម្ពីរដែលថ្លែងអំពីការដែលព្រះជាម្ចាស់បានធ្វើអ្វីដែលមនុស្សអាចធ្វើដែរ?" ជាឧទាហរណ៍ គម្ពីរទំនុកតម្កើង ៩៨ បានថ្លែងអំពី "ព្រះហស្តស្តាំ និងព្រះពាហុដ៏បរិសុទ្ធរបស់ទ្រង់" (ខ១
ពគប=ព្រះគម្ពីរបរិសុទ្ធបកប្រែនៅឆ្នាំ១៩៥៤ ) គម្ពីរទំនុកតម្កើង ៩៩:៥(ពគប) បាននិយាយអំពីការថ្វាយបង្គំ "ថ្វាយបង្គំនៅទៀបកំណល់កល់ព្រះបាទទ្រង់" គម្ពីរទំនុកតម្កើង ៩១(ពគប) និយាយអំពី "ស្លាបទ្រង់" និង "ចំអេងស្លាបរបស់ទ្រង់" (ខ៤) ។

ដោយសារតែការស្វែងយល់ពីសមាសភាពរបស់ព្រះជាម្ចាស់ មានការពិបាកសម្រាប់យើង ទ្រង់បានជំរុញចិត្តអ្នកនិពន្ធបទគម្ពីរ ឲ្យប្រើប្រាស់វត្ថុដែលយើងធ្លាប់ស្គាល់ ហើយប្រើប្រាស់លក្ខណៈខ្លះៗនៃវត្ថុទាំងនោះដើម្បីតំណាងឲ្យព្រះជាម្ចាស់។ ដោយធ្វើបែបនេះ យើងអាចទទួលបានការយល់ដឹងខ្លះៗ អំពីអ្វីដែលយើងមិនធ្លាប់ស្គាល់ តាមរយៈអ្វីដែលបានស្គាល់ហើយ។ នៅពេលដែលមានការតំណាងនេះត្រូវបានធ្វើឡើង យើងហៅការនេះថា ភាសានិមិត្តរូប ។ ក្នុងករណីនេះ ផ្នត់គំនិតនេះ មិនត្រូវចាត់ទុកជារឿងពិតមែន ឬ សេចក្ដីពិតនោះទេ ប៉ុន្តែត្រូវចាត់ទុកជានិមិត្តសញ្ញាដើម្បីតំណាងឲ្យគំនិតដែលពិតប្រាកដមួយ។ ការនេះអាចបញ្ជាក់ឲ្យច្បាស់នៅក្នុងលំហាត់ខាងក្រោម។

## *លំហាត់អនុវត្តន៍*

៤ ចូរអានគម្ពីរទំនុកតម្កើង ៣៤:១៥ ហើយគូសរង្វង់ជុំវិញព្យញ្ជនៈដែលនៅខាងមុខការបកស្រាយត្រូវសម្រាប់ខគម្ពីរនេះ។

ក) ការបង្ហាញអំពីព្រះជាម្ចាស់ ថាមាន ព្រះនេត្រ ព្រះកាណ៌ និង ព្រះភក្ត្រ បញ្ជាក់ថាទ្រង់ពិតជាអាចទតឃើញ ស្ដាប់ឮ និង មានទម្រង់ដែលអាចមើលឃើញនៅពេលដែលទ្រង់ទាក់ទងជាមួយមនុស្ស។

ខ) ព្រះជាម្ចាស់ជ្រាប និង យកព្រះទ័យទុកដាក់ ចំពោះតម្រូវការយុត្តិធម៌ ហើយទ្រង់ជ្រាប និង យកព្រះទ័យទុកដាក់នឹងភាពមានបាបរបស់អ្នកដែលធ្វើអំពើអាក្រក់។ ការទាំងនេះបង្ហាញឡើងតាមរបៀបនិមិត្តរូប។

៥ (ចូរជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវ)។ នៅពេលយើងអានបទគម្ពីរដែលថា ព្រះជាម្ចាស់ជាវិញ្ញាណ យើងអាចយល់បានថា

ក) ទ្រង់គ្មានព្រះកាយទេ។

ខ) ព្រះជាម្ចាស់មិនមានទម្រង់ជារូបកាយទេ ប៉ុន្តែទ្រង់អាចបង្ហាញអង្គទ្រង់តាមរយៈទម្រង់ដែលមានរូបបាន។

គ) ឯកសារយោងនៅក្នុងព្រះគម្ពីរដែលបង្ហាញថាព្រះជាម្ចាស់កំពុងធ្វើអ្វីដែលមនុស្សអាចធ្វើដោយប្រើភាសានិមិត្តរូប។

ឃ) ចម្លើយ ក) , ខ) និង គ) ជាចម្លើយត្រឹមត្រូវ។

ង) មានតែចម្លើយ ក) និង គ) ជាចម្លើយត្រឹមត្រូវ។

# ព្រះជាម្ចាស់មានតែមួយ

**វត្ថុបំណងទី៣.** *រៀបរាប់ និង កំណត់ន័យ ការរួបរួម និង ភាពតែមួយ របស់ព្រះជាម្ចាស់។*

នៅពេលដែលយើងនិយាយថា ព្រះជាម្ចាស់គឺមាន *តែមួយ* យើងចង់សំដៅទៅលើផ្នត់គំនិតបីយ៉ាង ៖ ទី១) *ការរួបរួម* ខាងឯចំនួនរបស់ព្រះជាម្ចាស់ ទី២) ភាព *ពិសេសប្លែក* របស់ព្រះជាម្ចាស់ និង ទី៣) *ពិសេសសាមញ្ញ* របស់ព្រះជាម្ចាស់។

## ការរួបរួមខាងឯចំនួនរបស់ព្រះជាម្ចាស់

ដំបូងឡើយ នៅពេលដែលយើងនិយាយអំពីការរួបរួមរបស់ព្រះជាម្ចាស់ យើងសំដៅទៅលើសេចក្ដីពិតដែលថា ទ្រង់គឺជាព្រះដែលមានចំនួនតែមួយ។ ដោយសារតែមានព្រះជាម្ចាស់តែមួយយ៉ាងដូច្នេះហើយ សភាវៈផ្សេងៗទៀតដែលចាត់កំណើតឡើងតាមរយៈទ្រង់តែមួយ សម្រាប់ទ្រង់តែមួយ និង ទៅកាន់ទ្រង់តែមួយ។ លោកប៉ូលមានប្រសាសន៍នៅក្នុងគម្ពីរ១កូរិនថូស៨:៦ " ក៏យើងជឿថា មានព្រះជាម្ចាស់តែមួយព្រះអង្គប៉ុណ្ណោះ។ ព្រះអង្គជាព្រះបិតាដែលបានបង្កើតអ្វីៗសព្វសារពើមក ហើយយើងមានជីវិតរស់សំរាប់ព្រះអង្គ។ យើងជឿទៀតថា មានព្រះអម្ចាស់តែមួយព្រះអង្គប៉ុណ្ណោះ គឺព្រះយេស៊ូគ្រិស្ត*។

អ្វីៗសព្វសារពើកើតមកដោយសារព្រះអង្គ ហើយយើងមានជីវិតរស់ក៏ដោយសារព្រះអង្គដែរ។" ផ្នែកទីពីរនៃខគម្ពីរនេះ ហាក់ដូចជាផ្ទុយនឹងគំនិតដែលថាព្រះជាម្ចាស់មានចំនួនតែមួយគត់។ ការនេះនឹងត្រូវលើកយកទៅបកស្រាយនៅពេលក្រោយក្នុងការពិភាក្សារបស់យើងស្តីពី *ព្រះត្រៃឯក* ។

ស្តេចសាឡូម៉ូន បានលើកឡើងពីភាពរួបរួមខាងឯចំនួន របស់ព្រះជាម្ចាស់នៅក្នុងគម្ពីរ១ពង្សាវតារក្សត្រ ៨:៦០ នៅពេលដែលទ្រង់សុំឲ្យ "ជាតិសាសន៍ទាំងអស់នៅលើផែនដីនឹងទទួលស្គាល់ថា មានតែព្រះអម្ចាស់ប៉ុណ្ណោះ ដែលពិតជាព្រះជាម្ចាស់ គឺគ្មានព្រះឯណាទៀតឡើយ។" ពេលខ្លះប្រជាជនអ៊ីស្រាអែលការលំបាកក្នុងការរក្សានូវគំនិតដែលថា ព្រះជាម្ចាស់គឺមានតែមួយ ព្រោះនៅជុំវិញប្រទេសគ្រប់ទិសទាំងអស់ មានប្រទេសជាច្រើនដែលនាំចូលព្រះជាច្រើនប្រភេទដែលអាចឲ្យពួកគេជ្រើសរើសបាន។ ជារឿយៗ ពួកព្យាការីធ្វើការស្រែកប្រកាសទាំងប្រថុយប្រថាន ទៅកាន់មនុស្សម្នាដើម្បីរំឭកពួកគេថា ព្រះយេហូវ៉ាគឺជាព្រះជាម្ចាស់តែមួយគត់ (គម្ពីរទុតិយកថា ៤:៣៥,៣៩)។

តើការជឿថាមានព្រះច្រើន គឺជាផ្នែកមួយនៅក្នុងសង្គមរបស់អ្នកដែរឬទេ? តើអ្នកបានស្គាល់សេចក្តីបង្រៀនណាទាក់ទងនឹងព្រះដែលកើតពីការសន្និដ្ឋាន និងទំនាក់ទំនងរបស់ព្រះទាំងនេះជាមួយមនុស្សដែរឬទេ? ខ្ញុំបានសំគាល់ឃើញថា នៅប្រទេសជាច្រើន ប្រជាជនបានថ្វាយបង្គំព្រះ ឬ អ្វីដែលគេចាត់ទុកថាជាព្រះយ៉ាងច្រើន។ ពេលខ្លះព្រះទាំងនោះ *ហាក់បីដូចជា* មានតែនៅក្នុងវប្បធម៌របស់ក្រុមកុលសម្ព័ន្ធ និងសម្រាប់ផ្នែកណាមួយនៅក្នុងជីវិតរបស់ពួកគេតែប៉ុណ្ណោះ ដែលបានន័យថាមានព្រះជាច្រើន ប៉ុន្តែនៅក្នុងព្រះគម្ពីរបានបង្រៀនអំពី *លក្ខណៈពិសេសតែមួយ* របស់ព្រះជាម្ចាស់ ដូច្នេះព្រះជាម្ចាស់អាចមានតែ *មួយអង្គគត់* ។

## លក្ខណៈពិសេសតែមួយរបស់ព្រះជាម្ចាស់

ខគម្ពីរផ្សេងទៀតនៅក្នុងព្រះគម្ពីរ ដូចជាគម្ពីរទុតិយកថា ៦:៤ និយាយពីលក្ខណៈពិសេសតែមួយរបស់ព្រះជាម្ចាស់ ៖ "មានតែព្រះអម្ចាស់ ជាព្រះរបស់យើង មួយព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់។" ពាក្យហេប្រឺដែលបកប្រែពាក្យថា *មួយ* ក៏អាចបកប្រែថា *តែមួយគត់* ដែលមើលទៅដូចជាការបកប្រែដែលល្អជាង។ ដូច្នេះ ព្រះយេហូវ៉ាតែមួយគត់ គឺជាព្រះតែមួយដែលទទួលបានព្រះនាម ថា ព្រះយេហូវ៉ានេះ។ នេះគឺជាសារក្នុងគម្ពីរសាការី ១៤:៩ "នៅថ្ងៃនោះ មនុស្សគ្រប់ៗគ្នានឹងថ្វាយបង្គំព្រះអម្ចាស់តែមួយព្រះអង្គគត់ គឺមានតែព្រះនាមព្រះអង្គប៉ុណ្ណោះ។ គំនិតដូចគ្នានេះក៏ត្រូវបានលើកយកទៅបង្ហាញយ៉ាងច្បាស់នៅក្នុងគម្ពីរនិក្ខមនំ ១៥:១១ "ព្រះអម្ចាស់អើយ តើមានព្រះណាអាចផ្ទឹមនឹងព្រះអង្គបាន? តើនរណាមានភាពថ្កុំថ្កើងដ៏វិសុទ្ធដូចព្រះអង្គ។ ព្រះអង្គជាព្រះគួរអោយកោតស្ញប់ស្ញែងគួរសរសើរតម្កើង ព្រះអង្គសំដែងឫទ្ធិបាដិហារិយ៍ដ៏អស្ចារ្យ។" ប្រាកដណាស់ ចម្លើយសម្រាប់សំណួរនេះគឺថា គ្មានព្រះណាទៀតទេ។ ទ្រង់គឺជាព្រះជាម្ចាស់តែមួយ ហើយមានតែព្រះអង្គមួយតែប៉ុណ្ណោះ។

ខគម្ពីរទាំងនេះ បានច្រានចោលការដែលថាព្រះជាម្ចាស់គឺជាព្រះមួយក្នុងចំណោមព្រះជាច្រើននោះ។ ទ្រង់គឺជាព្រះមហាក្សត្រនៃសាកលលោក ហើយក្រៅពីទ្រង់គ្មានព្រះណាទៀតនោះទេ។ នៅពាសពេញកំណត់ត្រាក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ ព្រះជាម្ចាស់បានក្រើនរំឭកប្រជារាស្ត្ររបស់ទ្រង់ថាទ្រង់គឺជា *ព្រះជាម្ចាស់តែមួយអង្គគត់*។

# *លំហាត់អនុវត្តន៍*

៦ ចូរអានបទគម្ពីរខាងក្រោម ហើយប្រាប់ពីអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលអំពីអង្គទ្រង់។

ក) គម្ពីរលោកុប្បត្តិ ១៧:១៖ "យើងជា........"

ខ) គម្ពីរនិក្ខមនំ ២០:២-៣ ៖ "យើង..................................................................
មិនត្រូវ......................................................"។

គ) គម្ពីរនិក្ខមនំ ២០:២៣(ពគប១៩៥៤) ៖ "ដូច្នេះមិនត្រូវ...........................................…"

ឃ) គម្ពីរអេសាយ ៤៣:១០-១១; ៤៤:៦,៨; ៤៥:៥,២១។ សារនៅក្នុងបទគម្ពីរនីមួយៗខាងក្រោមនេះគឺ ........................................................................."

---

នៅពេលដែលខ្ញុំសុំឲ្យសិស្សរបស់ខ្ញុំ ផ្ដល់និយមន័យផ្ទាល់ខ្លួនមួយអំពីព្រះជាម្ចាស់ ពួកគេតែងតែចាប់ផ្ដើមដោយនិយាយថា៖ "ព្រះជាម្ចាស់ជាវិញ្ញាណមួយ ដែលមានភាពអស់កល្ប ដែលបានបង្កើតផ្ទៃមេឃ និង ផែនដី។" មិនថានាមអ្វីដែលពួកគេប្រើសម្រាប់ផ្ដល់និយមន័យឲ្យព្រះជាម្ចាស់នោះទេ ពួកគេស្ទើតែគ្រប់គ្នាបានប្រើ គុណនាមវិសេសន៍មិនទៀងទាត់នៅពីក្រោយ។ ពួកគេនិយាយថា៖ "ព្រះជាម្ចាស់គឺជាវិញ្ញាណ*មួយ (a)* " ។ ការនិយាយបែបនេះបានធ្វើឲ្យយើងគិតថា អាចមានវិញ្ញាណផ្សេងទៀតដែលឋានៈស្មើគ្នាជាមួយព្រះអង្គ។ សូមមើលពីភាពខុសគ្នា ទៅលើនិយមន័យនេះ នៅពេលណាដែលយើងប្រើគុណនាមវិសេសន៍ទៀងទាត់ "*មួយគត់" (the)* ទៅជំនួសកន្លែងគុណនាមវិសេសន៍មិនទៀងទាត់ "មួយ (a)វិញ" ៖ "ព្រះជាម្ចាស់ជាវិញ្ញាណតែមួយគត់ ដែលមានភាពអស់កល្ប ដែលបានបង្កើតផ្ទៃមេឃ និងផែនដី"។ និយមន័យត្រូវតែឲ្យរបៀបបែបនេះ ដោយសារគ្មានមនុស្ស ឬ អំណាចណាដែលស័ក្ដិសមនៅក្នុងចំណាត់ថ្នាក់នេះឡើយ។ ព្រះជាម្ចាស់គឺជាព្រះតែមួយគត់។

## ភាពសាមញ្ញរបស់ព្រះជាម្ចាស់

លើសពីការរួបរួម និង លក្ខណៈពិសេសតែមួយ ការរួបរួមរបស់ព្រះជាម្ចាស់សំដៅទៅលើការរួបរួម*ផ្នែកខាងក្នុង* របស់ព្រះជាម្ចាស់។ ជារឿយ ការរួបរួមនៅក្នុងផ្នែកនេះ ត្រូវបានគេហៅថា *ភាពសាមញ្ញ។* ពាក្យថា ភាពសាមញ្ញមានន័យថាសភាព ឬ ស្ថានភាពដែលគ្មានការបែងចែកទៅជាផ្នែក។ ព្រះជាម្ចាស់ជា *វិញ្ញាណ* ដូច្នេះហើយទ្រង់មិនអាចមាននរណាបែងចែកបានឡើយ។ ផ្ទុយទៅវិញភាពជាមនុស្សរបស់យើង គឺជាការបណ្ដុំមួយ ៖ យើងគឺជាវត្ថុធាតុ (ខ្លួនប្រាណ) និង ជារបស់អរូប (វិញ្ញាណ)។

អ្វីៗគ្រប់យ៉ាងអំពីព្រះជាម្ចាស់គឺល្អឥតខ្ចោះ។ យើងអាចនិយាយម្យ៉ាងទៀតបានថា លក្ខណសម្បត្តិរបស់ព្រះគឺជា*ភាពល្អឥតខ្ចោះ* របស់ទ្រង់។ ការគិតអំពីភាពរួបរួមនៅខាងក្នុង ឬ ភាពសាមញ្ញ នៅបន្ទាប់ពីភាពឥតខ្ចោះផ្សេងៗទៀតរបស់ព្រះជាម្ចាស់។ ឧទាហរណ៍ អត្ថិភាពរបស់ព្រះជាម្ចាស់ គឺមិនផ្អែកទៅលើអ្វីដែលនៅខាងក្រៅទ្រង់នោះទេ ។ ព្រះជាម្ចាស់គឺ*កើតឡើងដោយអង្គឯង* ដែលមានន័យថា អត្ថិភាពនៅអស់កល្បជានិច្ច គឺជាផ្នែកមួយនៃលក្ខណៈរបស់ទ្រង់ផ្ទាល់។ ដូច្នេះ អត្ថិភាពដោយអង្គឯងរបស់ទ្រង់នេះ ច្រានចោលនូវផ្នត់គំនិតដែលថា មានអ្វីម្យ៉ាងបានបង្កើតទ្រង់ឡើង ដូចនៅក្នុងករណីរបស់

ភាវៈដែលកើតពីបណ្តុំ ដូចជាមនុស្សជាដើម។ *ភាពសាមញ្ញ* របស់ព្រះជាម្ចាស់បញ្ជាក់ឲ្យឃើញពីរឿងមួយចំនួន ។ រឿងមួយគឺថា អង្គទាំងបីនៃត្រៃឯកភាពពេញលេញ(ភាពពេញលេញរបស់ព្រះត្រៃឯក) គឺមិនគ្រាន់តែជាផ្នែកមួយដែល មករួមគ្នាបង្កើតបានជាសមាសភាពរបស់ព្រះជាម្ចាស់នេះឡើយ។ រឿងនេះក៏មិនឲ្យមាន ការចែកដាច់ភាពឥតខ្ចោះរបស់ព្រះជាម្ចាស់ ចេញពីសមាសភាពរបស់ទ្រង់ ឬ ការបន្ថែមលក្ខណសម្បត្តិរបស់ទ្រង់ទៅលើសមាសភាពរបស់ព្រះជាម្ចាស់ផងដែរ។ សមាសភាពរបស់ព្រះជាម្ចាស់ និង ភាពឥតខ្ចោះរបស់ទ្រង់ គឺតែមួយ និង ជារបស់ដូចគ្នា។ ដូច្នេះ បទគម្ពីរដែលនិយាយអំពីព្រះជាម្ចាស់ ថាទ្រង់ជាពន្លឺ និង ជាជីវិត ភាពសុចរិត និង សេចក្តីស្រឡាញ់ ហើយតាមរបៀបនេះ បានរាប់ទ្រង់ចូលជាមួយភាពឥតខ្ចោះរបស់ទ្រង់ដែរ។ ម្យ៉ាងទៀត យើងមិននិយាយថាព្រះជាម្ចាស់ *មាន* ភាពសុចរិតនោះទេ ប៉ុន្តែយើងនិយាយថា ទ្រង់*គឺជា* ភាពសុចរិតវិញ។ ទ្រង់*គឺជា* ភាពល្អឥតខ្ចោះ!

## *លំហាត់អនុវត្តន៍*

៧ ចូរផ្គូផ្គងគំនិតដែលប្រើដើម្បីរៀបរាប់អំពីភាពរួបរួមរបស់ព្រះជាម្ចាស់ ទៅជាមួយនឹងនិយមន័យនៃគំនិតនីមួយៗ។

.........ក) ទ្រង់គឺជាព្រះជាម្ចាស់តែមួយ និង គ្មានព្រះឯណាដូចទ្រង់ឡើយ។

.........ខ) មានព្រះជាម្ចាស់មួយអង្គ ហើយសភាវៈផ្សេងៗទៀតកើតមានឡើងតាមរយៈទ្រង់។

.........គ) គំនិតនេះប្រានចោល អ្វីដែលអាចបណ្តាលឲ្យពហុភាពនៃព្រះជាម្ចាស់។

........ឃ) អត្ថិភាពរបស់ព្រះជាម្ចាស់មិនផ្អែកទៅលើអ្វីដែលនៅខាងក្រៅទ្រង់នោះទេ។

........ង) នេះគឺជារបៀបមួយទៀតដែលរៀបរាប់អំពីភាពរួបរួមផ្នែកខាងក្នុងរបស់ព្រះជាម្ចាស់។

.........ច) យើងគឺជាបណ្តុំ ដែលមានន័យថា យើងគឺជាខ្លួនប្រាណ និង វិញ្ញាណ ផ្ទុយពីព្រះជាម្ចាស់ដែលទ្រង់ជាវិញ្ញាណ។

.........ឆ) ព្រះជាម្ចាស់គឺជាវិញ្ញាណដ៏អស់កល្បជានិច្ច។

១) ភាពរួបរួមខាងឯចំនួន

២) ភាពពិសេសតែមួយ

៣) ភាពសាមញ្ញ

# ព្រះជាម្ចាស់ជាព្រះបីរួមមកតែមួយ

**វត្ថុបំណងទី៤.** *បកស្រាយសេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរអំពីព្រះត្រៃឯក។*

យើងបានឃើញហើយថា ព្រះជាម្ចាស់ជាវិញ្ញាណ ទ្រង់ជាព្រះដែលមានភាពជាបុគ្គល ហើយទ្រង់មានតែមួយ។ ឥឡូវនេះយើងពិចារណាទៅលើផ្នែកទីបួននៅក្នុងនិស្ស័យរបស់ទ្រង់៖ នោះគឺព្រះត្រៃឯក ។ ព្រះជាម្ចាស់គឺជា *បីរួមមកតែមួយ* ។ ការនេះប្រហែលជាគួរឲ្យងឿងឆ្ងល់បន្តិចសម្រាប់អ្នក។ តើព្រះជាម្ចាស់ជា *ព្រះមួយអង្គ* និង ជា *ព្រះបីអង្គរួមមកតែមួយ* យ៉ាងដូចម្ដេចបាន? ពាក្យថា *បីរួមតែមួយ* ឬ *ត្រៃឯក* មានផ្ទុកនូវផ្នត់គំនិតពីភាពតែមួយ ឬ បី (ត្រី) និង ភាពតែមួយ ឬ សភាពដែលមាន *បីក្នុងមួយ ។* នៅពេលដែលយើងសិក្សាមុខវិជ្ជាដ៏សំខាន់មួយនេះ យើងឃើញថា យើងអាចដឹងសេចក្ដីពិតនេះ តាមរយៈការបើកបង្ហាញរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ ដូច្នេះ យើងបែរទៅមើលអ្វីដែលព្រះជាម្ចាស់បានបង្ហាញ នៅក្នុងបទគម្ពីរ ទុកជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សារបស់ទៅលើសំណួរខាងក្រោមដែលទាក់ទងនឹងព្រះត្រៃឯក។

១. *តើព្រះត្រៃឯកជាអ្វី?*

ដូចដែលយើងបានឃើញហើយថា មានសមាសភាពតែមួយគត់នៅក្នុងភាពជាព្រះជាម្ចាស់។ ប៉ុន្តែព្រះជាម្ចាស់មួយអង្គគត់នេះ គឺជាបុគ្គលិកលក្ខណៈបីយ៉ាង ឬ ព្រះត្រៃឯក។ នៅក្នុងទ្រង់មានព្រះ *បី* អង្គ ៖ ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ។ អ្នកប្រាជ្ញដែលព្យាយាមរៀបរាប់យ៉ាងក្បោះក្បាយ ពីភាពខុសគ្នាទាំងនេះនៅក្នុងត្រៃឯកភាពពេញលេញ បានប្រើប្រាស់ពាក្យខុសៗគ្នា។ ពាក្យខុសៗគ្នាដែលពួកគេបានប្រើ បានប្រាប់ឲ្យដឹងថា អ្នកប្រាជ្ញទាំងនេះ បានយល់ពីភាពលំបាកក្នុងការរៀបរាប់ពីព្រះត្រៃឯក។ យើងបានកំណត់និយមន័យនៃពាក្យ *បុគ្គល* រួចមកហើយ។ បុគ្គល គឺជាអ្នកដឹង ទទួលអារម្មណ៍ និង ធ្វើការសម្រេចចិត្ត។

បទពិសោធន៍របស់មនុស្សបង្រៀនយើង ថាកន្លែងណាមានមនុស្ស កន្លែងនោះមានសមាសភាពខុសៗគ្នា។ ដូច្នេះ មនុស្សគ្រប់រូបគឺខុសពីគ្នា ហើយការដកចេញភាពជាបុគ្គលដែលមាននៅក្នុងពួកគេ បានបង្ហាញឲ្យឃើញពីនិស្ស័យរបស់មនុស្ស។ ប៉ុន្តែនៅក្នុងព្រះបីរួមមកតែមួយ គឺគ្មានបុគ្គលបីផ្សេងៗគ្នា ដែលរស់នៅជាមួយគ្នា ឬ អាចចែកដាច់ចេញពីគ្នានោះឡើយ។ ផ្ទុយទៅវិញ មានតែអ្វីម្យ៉ាងដែលយើងអាចហៅថា *ភាពខុសគ្នាកើតឡើងដោយខ្លួនឯង* ដែលមាននៅក្នុងសមាសភាពរបស់ព្រះជាម្ចាស់ ។ ពាក្យនេះនឹងត្រូវលើកទៅបកស្រាយនៅក្នុងកថាខណ្ឌបន្ទាប់ទៀតនេះ។

២. *តើបុគ្គលម្នាក់ៗនោះគឺជានរណា?*

ដូចដែលយើងបានដឹងហើយថា មានតែព្រះ ឬ អត្ថិភាពបីយ៉ាងតែប៉ុណ្ណោះនៅក្នុងសមាសភាពរបស់ព្រះជាម្ចាស់៖ ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះទាំងបីព្រះអង្គនេះ ត្រូវបានគេស្គាល់តាមរយៈ *លក្ខណៈសម្បត្តិ* (គុណសម្បត្តិ ឬ លក្ខណៈពិសេសៃដែលជារបស់បុគ្គលម្នាក់ និង ចម្លែកសម្រាប់បុគ្គលម្នាក់)។ នៅក្នុងបទគម្ពីរ លក្ខណសម្បត្តិទាំងនេះត្រូវបានគេស្គាល់តាមរយៈ ងារ សព្វនាម គុណសម្បត្តិ និង សកម្មភាព ដែលចាំបាច់សម្រាប់ធ្វើការឲ្យហេតុផល សម្រាប់បញ្ហា និង បុគ្គលខុសប្លែកគ្នា។ លក្ខណៈសម្បត្តិផ្ទាល់ខ្លួនទាំងនេះ មានលក្ខណៈដោយឡែកទៅតាមបុគ្គលម្នាក់ៗ

(ទាំងនេះគឺ *ភាពខុសគ្នាកើតឡើងដោយខ្លួនឯង* ) ហើយលក្ខណៈសម្បត្តិទាំងនេះ បង្ហាញពីទំនាក់ទំនងរបស់មនុស្សម្នាក់ទៅកាន់អ្នកដទៃផ្សេងទៀត។ ក៏ដូចគ្នាផងដែរ លក្ខណសម្បត្តិនីមួយនៅក្នុងទ្រង់ផ្ទាល់បង្ហាញឲ្យឃើញពីសមាសភាពរបស់ព្រះជាម្ចាស់។

ដូច្នេះ មានព្រះបីអង្គនៅក្នុងត្រៃឯកភាពពេញលេញ៖ ព្រះជាម្ចាស់ព្រះវរបិតា ព្រះជាម្ចាស់ព្រះរាជបុត្រា និង ព្រះជាម្ចាស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះទាំងបីព្រះអង្គមានសារធាតុដូចគ្នា ទ្រង់មានសិរីរុងរឿង ឫទ្ធានុភាព ព្រះតេជៈ និង ភាពអស់កល្បជានិច្ចស្មើគ្នា ហើយទ្រង់គឺជាព្រះតែមួយ។

## លំហាត់អនុវត្តន៍

---

៨ ចូរអានបទគម្ពីរនៅខាងក្រោម ហើយសរសេរចម្លើយត្រឹមត្រូវ ក្នុងការបំពេញប្រយោគខាងក្រោមនេះដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) នៅក្នុងគម្ពីរយ៉ូហាន ៦:២៧ ព្រះយេស៊ូមានព្រះបន្ទូលថា ព្រះជាម្ចាស់ជា..........................

ខ) នៅក្នុងគម្ពីរហេប្រឺ ១:៨ ព្រះជាម្ចាស់ព្រះវរបិតា មានព្រះបន្ទូលថាព្រះរាជបុត្រា ជា...............

គ) គម្ពីរកិច្ចការ ៥:៣-៤ ថ្លែងប្រកាសថា អំពើបាបទាស់នឹងព្រះវិញ្ញាណដ៏វិសុទ្ធគឺដូចជាអំពើបាបទាស់នឹង.......................................................................................................

ឃ)តាមរយៈបទគម្ពីរនេះយើងអាចធ្វើការសន្និដ្ឋានបានថានៅក្នុងត្រៃឯកភាពពេញលេញមាន........

---

៣. *តើមានភស្តុតាងអ្វីសម្រាប់បង្ហាញពីព្រះត្រៃឯក?*

ស្របពេលដែលពាក្យថា *ព្រះត្រៃឯក* គ្មាននៅព្រះគម្ពីរ មានសេចក្ដីបង្រៀនជាច្រើនអំពីព្រះត្រៃឯកត្រូវបានបង្ហាញឲ្យឃើញនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ផង និង គម្ពីរសម្ព័ន្ធមេត្រីថ្មីផង។ ចូរឲ្យយើងបានក្រឡេកទៅមើលពីភស្តុងតាងខ្លះៗ ដែលយើងរកឃើញនៅក្នុងបទគម្ពីរ។

ព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ត្រូវបានសរសេរឡើង ជាភាសាហេប្រឺ។ នៅក្នុងភាសាហេប្រឺ ព្រះនាមសម្រាប់ប្រើជាមួយព្រះជាម្ចាស់គឺ *អ៊ីឡូហ៊ិម (Elohim)* ជាទម្រង់ពហុវចនៈ ជាឧទាហរណ៍ នៅក្នុងគម្ពីរលោកុប្បត្តិ ១:២៦ "ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «យើងបង្កើតមនុស្សជាតំណាងរបស់យើង មានលក្ខណៈដូចយើង"។ ខគម្ពីរចង្អុលទៅកាន់ភាពដោយឡែកគ្នាខាងឯអង្គព្រះ នៅក្នុងព្រះជាម្ចាស់ និងទៅកាន់ពហុភាពនៃអង្គព្រះ នៅក្នុងត្រៃឯកភាពពេញលេញ។ យើងរកឃើញភស្តុតាងកាន់តែច្បាស់អំពីភាពដោយឡែកគ្នានៃអង្គព្រះ នៅក្នុងបទគម្ពីរសម្ព័ន្ធមេត្រីចាស់ ដែលនិយាយអំពីទេវតារបស់ព្រះយេហូវ៉ា។ នៅក្នុងករណីខ្លះ ទេវតារបស់ព្រះអម្ចាស់អាចសំដៅទៅលើសភាវៈមួយប្រភេទដែលត្រូវបានចាត់មកជាអ្នកនាំសាររបស់ព្រះអម្ចាស់ ចំណែកឯនៅក្នុងករណីផ្សេងទៀត ទេវតានោះត្រូវបានគេជឿថា ជាបុត្ររបស់ព្រះជាម្ចាស់ ( សូមមើលគម្ពីរលោកុប្បត្តិ ១៦:៧-១៣; ១៨:១-២១; ១៩:១-២៨)។ ដូចនេះ ទេវតានេះក៏ត្រូវបានសំគាល់រួមជាមួយព្រះយេហូវ៉ា ប៉ុន្តែលោកត្រូវបានគេឃើញថាដាច់ដោយឡែក ឬ ខុសពីព្រះយេហូវ៉ា។

មានពេលខ្លះ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ មាននិយាយអំពីព្រះច្រើនជាងមួយអង្គ (សូមមើលគម្ពីរទំនុកតម្កើង ៤៥:៦-៧ ហើយប្រៀបធៀបជាមួយនឹងគម្ពីរហេប្រឺ ១:៨-៩)។ នៅពេលខ្លះទៀត ព្រះជាម្ចាស់

ដែលជាអ្នកមានព្រះបន្ទូលយ៉ាងច្បាស់នោះ បានមានព្រះបន្ទូលអំពីព្រះមេស្ស៊ី (ព្រះរាជបុត្រា) និង ព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរអេសាយ ៤៨:១៦; ៦១:១; ៦៣:៨-១០)។

ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីផ្តល់នូវការបើកបង្ហាញយ៉ាងច្បាស់ អំពីការចាត់ព្រះរាជបុត្រារបស់ទ្រង់មកក្នុងពិភពលោក (គម្ពីរយ៉ូហាន ៣:១៦ គម្ពីរកាឡាទី ៤:៤ គម្ពីរ១យ៉ូហាន ៤:៩)។ គម្ពីរនេះក៏បានបង្ហាញឲ្យឃើញពីព្រះវរបិតា និង ព្រះរាជបុត្រាដែលបានចាត់បញ្ជូនព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរយ៉ូហាន ១៤:២៦; ១៥:២៦;១៦:៧)។ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី យើងបានឃើញថា ព្រះវរបិតាមានព្រះបន្ទូលទៅកាន់ព្រះរាជបុត្រា (គម្ពីរម៉ាកុស១:១១ គម្ពីរលូកា៣:២២) ព្រះរាជបុត្រាមានទំនាក់ទំនងជាមួយព្រះវរបិតា (គម្ពីរម៉ាថាយ១១:២៥-២៦ គម្ពីរយ៉ូហាន ១១:៤១; ១២:២៧-២៨) និង ព្រះវិញ្ញាណដ៏វិសុទ្ធអធិស្ឋានទៅកាន់ព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់អ្នកជឿ (គម្ពីររ៉ូម៨:២៦-២៧) ។ ដូច្នេះ នៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី អង្គព្រះដែលចែកដាច់គ្នានៅក្នុងព្រះត្រៃឯក បានបង្ហាញពីភាពដោយឡែកគ្នារបស់ព្រះជាម្ចាស់នៅចំពោះមុខយើង។

នៅក្នុងបទគម្ពីរខ្លះ មាននិយាយអំពី អង្គព្រះទាំងបីនៃត្រៃឯកភាពពេញលេញតែម្តង។ នៅក្នុងសាច់រឿងនៃការជ្រមុជទឹករបស់ព្រះរាជបុត្រា (គម្ពីរម៉ាថាយ ៣:១៦-១៧) ព្រះវរបិតាមានព្រះបន្ទូលពីស្ថានបរមសុខមក ហើយព្រះវិញ្ញាណដ៏វិសុទ្ធបានយាងចុះមកនៅក្នុងសណ្ឋានជាសត្វព្រាប។ នៅក្នុងសាច់រឿងមហាបេសកម្ម (គម្ពីរម៉ាថាយ ២៨:១៩) ព្រះយេស៊ូបានមានព្រះបន្ទូលអំពីព្រះបីអង្គ៖ "ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" ។ ការថ្លែងពីព្រះនាមព្រះទាំងបីអង្គនៅជាប់ៗគ្នានេះ ក៏មាននៅក្នុងគម្ពីរ១កូរិនថូស ១២:៤-៦ គម្ពីរ២កូរិនថូស ១៣:១៤ និងគម្ពីរ១ពេត្រុស ១:២ ។ តាមរយៈឧទាហរណ៍ទាំងនេះ យើងអាចរកឃើញភស្តុតាងជាច្រើន សម្រាប់គោលលទ្ធិអំពីព្រះត្រៃឯក។

## *លំហាត់អនុវត្តន៍*

៩ ចូរផ្គូផ្គងឃ្លាបង្គប់(ខាងស្តាំ) ទៅនឹងខគម្ពីរយោងដែលត្រឹមត្រូវ (ខាងឆ្វេង)។

| | | | |
|---|---|---|---|
| .........ក) | គម្ពីរលោកុប្បត្តិ ១:២៦ ចង្អុលទៅកាន់............. | ១) | ព្រះវិញ្ញាណដ៏វិសុទ្ធ |
| .........ខ) | គម្ពីរអេសាយ៦៣:៨-១០ បង្ហាញថាព្រះយេហូវ៉ាមានទំនាក់ទំនងជាមួយនឹង................................ | ២) | ព្រះប្រោសលោះ ឬ ព្រះសង្គ្រោះ |
| ..........គ) | គម្ពីរយ៉ូហាន ៣:១៦ បង្ហាញថា ព្រះជាម្ចាស់បានចាត់បញ្ជូនព្រះរាជបុត្រាមកដើម្បីជា.......................... | ៣) | ព្រះសង្គ្រោះ និង ព្រះវិញ្ញាណដ៏វិសុទ្ធ |
| ..........ឃ) | គម្ពីរយ៉ូហាន១៤:២៦ និង ១៥:២៦ បញ្ជាក់ថាព្រះវរបិតា និង ព្រះរាជបុត្រា បានចាត់បញ្ជូន........................... ដែលសណ្ឋិតនៅក្នុងអ្នកជឿ។ | ៤) | អង្គព្រះនៅក្នុងព្រះត្រៃឯក |
| | | ៥) | ពហុភាពនៃអង្គព្រះ |
| ...........ង) | គម្ពីរម៉ាថាយ ៣:១៦-១៧ និង ២៨:១៩ បង្ហាញ និង ប្រាប់ពីនាមរបស់........................................។ | | |

៤. *តើអ្វីខ្លះជាការលំបាកនៅក្នុងគោលលទ្ធិ?*

ហេតុអ្វីបានជាសេចក្ដីបង្រៀនអំពីព្រះត្រៃឯកមានការលំបាកសម្រាប់ឲ្យពួកយើងស្វែងយល់ម្ល៉េះ? នៅក្នុងបទពិសោធន៍ជាមនុស្សយើងគ្មានអ្វី ដើម្បីយកមកប្រៀបធៀប ទៅនឹង*ព្រះត្រៃឯកដែលរួមមកតែមួយ* ឬ *ការរួមមកតែមួយរបស់ព្រះត្រៃឯក។* យើងដឹងថាគ្មានមនុស្សបីនាក់ផ្សេងគ្នាណា ដែលមានរូបរាងជាមនុស្សតែមួយនោះទេ។ គ្មានមនុស្សបីនាក់ ដែលអាចដឹងពីអ្វីដែលពួកគេធ្វើ និង គិតទៅវិញទៅមកនោះទេ។ បុគ្គលម្នាក់ៗនៅក្នុងចំណោមពួកគេ គឺសុទ្ធតែមាននវនាំងផ្ទាល់ខ្លួនរបស់ពួកគេ។ គ្មានមនុស្សណាអាចមាន លក្ខណៈបីរួមមកតែមួយដូចជាព្រះជាម្ចាស់នោះទេ។ មនុស្សមិនបកស្រាយ សេចក្ដីបង្រៀនទាក់ទងនឹងព្រះត្រៃឯកបាន ដោយផ្អែកទៅលចំណេះដឹង និង បទពិសោធន៍ជាមនុស្សរបស់ពួកគេបាននោះទេ។

៥. *តើយើងអាចដោះស្រាយការលំបាកនោះបានដោយរបៀបណា?*

បញ្ហាគោលនៅក្នុងការព្យាយាមបកស្រាយអំពីព្រះត្រៃឯក គឺផ្អែកទៅលើទំនាក់ទំនងនៃអង្គព្រះនៅក្នុងត្រៃឯកភាពពេញលេញ ទៅនឹងសមាសភាពរបស់ព្រះជាម្ចាស់ និង ទៅនឹងអង្គព្រះនីមួយៗ ទៅវិញទៅមក។ បញ្ហានេះគឺជាបញ្ហាមួយដែលក្រុមជំនុំមិនអាចដកចេញបាននោះទេ។ ក្រុមជំនុំអាចត្រឹមតែព្យាយាមកាត់បន្ថយបញ្ហាដោយការផ្ដល់នូវនិយមន័យសមរម្យទៅឲ្យពាក្យនីមួយៗតែប៉ុណ្ណោះ។ ទោះបីជា ក្រុមជំនុំមិនធ្លាប់បានព្យាយាយបកស្រាយ អាថ៌កំបាំងនៃព្រះត្រៃឯកក៏ដោយ ក៏ពួកគេនៅតែបានព្យាយាមរៀបចំសេចក្ដីបង្រៀនយ៉ាងច្បាស់លាស់អំពីការនោះផងដែរ ជាចម្បងគឺដើម្បីលុបបំបាត់កំហុសដែលចោទជាការគំរាមកំហែង ទៅដល់ក្រុមជំនុំទាំងមូលតែម្ដង។ តាមរយៈការប្រៀបធៀបបទគម្ពីរ ទៅនឹងបទគម្ពីរ យើងអាចឃើញពីគោលលទ្ធិនៃព្រះត្រៃឯក ក្នុងកម្រិតមួយដែលព្រះជាម្ចាស់បានបើកបង្ហាញពីសេចក្ដីបង្រៀននោះនៅក្នុងព្រះបន្ទូលរបស់ទ្រង់ ទោះបីជាយើងនឹងមិនទាន់អាចស្វែងយល់ពីសេចក្ដីបង្រៀនពេញលេញក៏ដោយ។

នៅក្នុងអត្ថិភាព ដែលមានកម្រិត (មានដែនកំណត់)របស់យើង យើងមិនអាចបកស្រាយឲ្យបានក្បោះក្បាយពីភាពគ្មានកម្រិត (ដែលគ្មានដែនកំណត់)បាននោះទេ។ លោកប៉ូលបានរៀបរាប់ភាពមានកម្រិតរបស់មនុស្សមួយនេះ នៅក្នុងសំបុត្រទីមួយរបស់លោកទៅកាន់អ្នកក្រុងកូរិនថូសថា៖ "សព្វថ្ងៃនេះយើងស្គាល់ព្រះជាម្ចាស់មិនច្បាស់ទេ គឺស្គាល់ព្រាលៗដូចជាមើលក្នុងកញ្ចក់ នៅពេលខាងមុខ ទើបយើងឃើញព្រះអង្គទល់មុខគ្នា។ សព្វថ្ងៃ ខ្ញុំស្គាល់ព្រះអង្គបានត្រឹមតែមួយផ្នែកប៉ុណ្ណោះ ពេលខាងមុខទើបខ្ញុំស្គាល់ព្រះអង្គច្បាស់ ដូចព្រះអង្គស្គាល់ខ្ញុំយ៉ាងច្បាស់ដែរ។" (គម្ពីរ១កូរិនថូស ១៣:១២)។

# **លំហាត់អនុវត្តន៍**

១០ នៅក្នុងចំណោមប្រយោគខាងក្រោមនេះ ចូរជ្រើសរើសប្រយោគណាដែលត្រឹមត្រូវ ដោយយោងទៅតាមបទគម្ពីរដែលទាក់ទងនឹងព្រះត្រៃឯក និង យោងទៅតាមការយល់ដឹងរបស់យើងអំពីព្រះត្រៃឯកនោះ។

ក) ព្រះគម្ពីរបានបង្ហាញពីមានអង្គព្រះចំនួនបីអង្គនៅក្នុងលក្ខណៈវិសេសន៍របស់ព្រះជាម្ចាស់។

ខ) ព្រះទាំងបីអង្គ ដែលមានព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ មានលក្ខណៈដោយឡែកពីគ្នា ដែលបានរៀបរាប់ដោយប្រើប្រាស់ងារ សព្វនាម គុណសម្បត្តិ និង សកម្មភាព ដែលយកទៅប្រើលើអង្គព្រះដោយឡែកផ្សេងគ្នានោះ។

គ) ព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ មិនបានថ្លែងអំពីពហុភាពនៃអង្គព្រះនៅក្នុងត្រៃឯកភាពពេញលេញនោះទេ តែគម្ពីរនេះគ្រាន់តែថ្លែងអំពីព្រះជាម្ចាស់ព្រះយេហូវ៉ាតែប៉ុណ្ណោះ។

ឃ) ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី បង្ហាញពីអង្គព្រះនៅក្នុងព្រះត្រៃឯក បានពេញលេញជាងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ទៅទៀត។

ង) ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី ផ្តល់មូលដ្ឋានគ្រឹះដែលដកស្រង់ពីបទគម្ពីរយ៉ាងគ្រប់គ្រាន់សម្រាប់គោលលិទ្ធិអំពីព្រះត្រៃឯក។

ច) បញ្ហាចម្បង ជាមួយនឹងការយល់ដឹងរបស់យើងអំពីអង្គព្រះទាំងបីអង្គដែលមាននៅក្នុងព្រះជាម្ចាស់ គឺថាយើងគ្មានអ្វីមួយដែលនៅក្នុងបទពិសោធន៍ ដើម្បីធ្វើការប្រៀបធៀបជាមួយភាពដោយឡែកគ្នានៃលក្ខណៈបីរួមមកតែមួយរបស់ព្រះជាម្ចាស់បានឡើយ។

ឆ) យើងអាចដោះស្រាយបញ្ហាអំពីព្រះត្រៃឯកបានយ៉ាងល្អ តាមរយៈការដឹងថា ដោយបញ្ហានេះមិនអាចបកស្រាយបានយ៉ាងពេញលេញ យើងមិនគួរព្យាយាមបង្កើតគោលលទ្ធិ (សេចក្តីបង្រៀន) អំពីបញ្ហានេះសោះឡើយ។

ការសិក្សាយ៉ាងយកចិត្តទុកដាក់ទៅលើព្រះបន្ទូល បង្ហាញឲ្យយើងបានឃើញយ៉ាងច្រើនអំពីភាពបីរួមមកតែមួយរបស់ព្រះជាម្ចាស់។ ការសិក្សាប្រកបដោយការផ្ចង់ចិត្ត ទៅលើគោលលិទ្ធិនេះ ជួយឲ្យយើងយល់ដឹងកាន់តែប្រសើរឡើងអំពី ការបើកបង្ហាញរបស់ព្រះជាម្ចាស់អំពីអង្គទ្រង់ ទោះបីជាការយល់ដឹងបានត្រឹមតែមួយផ្នែកក៏ដោយ។ វាក៏ជួយយើងឱ្យយល់កាន់តែច្បាស់អំពីលក្ខណៈនៃព្រះ និងមធ្យោបាយដែលទ្រង់បានផ្តល់សម្រាប់យើងដើម្បីចូលទៅរកទ្រង់ដោយសេចក្តីស្រឡាញ់ ការថ្វាយបង្គំ និងការបម្រើដោយលះបង់។

## ព្រះជាម្ចាស់គឺជាព្រះដែលមានតាពអស់កល្បជានិច្ច

វត្ថុបំណងទី៥. *បង្ហាញពីការជាប់ពាក់ព័ន្ធសម្រាប់គ្រិស្តបរិស័ទទៅនឹងភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់។*

មានមនុស្សជាច្រើននាក់ ចាប់អារម្មណ៍ទៅលើការស្វែងរកឲ្យដឹងថាតើដូនតារបស់ពួកគេមកពីណា។ តើអ្នកនឹងគិតយ៉ាងណាដែរ ប្រសិនបើខ្ញុំប្រាប់អ្នកថាខ្ញុំគ្មានដូនតានោះទេ។ អ្នកអាចនឹងមិនទទួលស្គាល់ការនោះថាជាការពិតនោះទេ ហើយអ្នកពិតជាត្រឹមត្រូវហើយ។ ខ្ញុំក៏មានដូនតា ដូចជាមនុស្សគ្រប់គ្នាដែរ។

ខ្ញុំសូមនិយាយថា មនុស្សគ្រប់គ្នាសុទ្ធតែមានដូនតារៀងៗខ្លួន ប៉ុន្តែខ្ញុំមិនរាប់បញ្ចូលព្រះជាម្ចាស់នៅក្នុងចម្លើយនោះទេ។ ទ្រង់គ្មានដូនតាអ្វីឡើយ។ ដូច្នេះ តើទ្រង់មានប្រភពកំណើតមកពីណា? សំណួរនេះមានចម្លើយដ៏សាមញ្ញមួយ។ ទ្រង់គ្មានប្រភពកំណើតអ្វីនោះទេ! ទ្រង់បានមានព្រះជន្មគង់នៅ រហូតមកហើយ តាំងពីដរាបមកម្ល៉េះ។ ហេតុនោះហើយបានជាយើងអាចនិយាយបានថា *ព្រះជាម្ចាស់គឺព្រះដែលមានភាពអស់កល្បជានិច្ច។*

១. *តើអ្វីជាភាពអស់កល្បជានិច្ច?*

ការស្រម៉ៃគិតពីអនាគតដែលគ្មាននរណាម្នាក់អាចដឹង ជាការពិបាកសម្រាប់យើងខ្លាំងណាស់ ប៉ុន្តែយើងប្រហែលជាអាចគិតស្រម៉ៃត្រឡប់ទៅរកអតីតកាលឲ្យបានឆ្ងាយតាមតែគំនិតរបស់យើងអាចគិតដល់ ហើយព្យាយាមគិតពីភាពអស់កល្បជានិច្ច។ យើងចាត់ទុកថាគម្ពីរលោកុប្បត្តិជាគម្ពីរអំពីការចាប់ផ្តើម ។ នៅក្នុងគម្ពីរនេះ យើងសិក្សាអំពីទីចាប់ផ្តើមនៃរបស់សព្វសារពើ ការចាប់ផ្តើមរបស់មនុស្សជាតិ និង ការចាប់ផ្តើមនៃប្រជាជាតិទាំងអស់។ ប៉ុន្តែការចាប់ផ្តើមដ៏នៅសែនឆ្ងាយនេះ មិនមែនជា*ការចាប់ផ្តើមដំបូងបង្អស់* នោះទេ។

យើងអាចត្រឡប់ទៅមើលពីអតីតកាលកាន់តែឆ្ងាយថែមទៀត ជាពេលដែលទេវតាត្រូវបានបង្កើតឡើង គឺបុត្រដ៏ពិសេស នៅស្ថានសួគ៌(ស្ថានបរមសុខ) របស់ព្រះជាម្ចាស់ ដែលស្រែកឡើងទាំងអំណរ នៅកាលដែលគ្រឹះនៃផែនដីបានចាក់ឡើង តាំងពីមុនការចាប់ផ្តើមនៃប្រវត្តិសាស្ត្រ (គម្ពីរយ៉ូប ៣៨:៤-៧)។ នោះក៏មិនមែនជាការចាប់ផ្តើមដំបូងបង្អស់នោះដែរ។ នៅក្នុងគំនិតរបស់យើង យើងប្រហែលជាយល់ឃើញថាភាពអស់កល្បជានិច្ច គឺជាភាពមិនចេះចប់មិនចេះហើយ គ្មានដែនកំណត់ (គ្មានព្រំដែន) ដែលរបស់សព្វសារពើមានតែនៅក្នុងព្រះតម្រិះរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ នេះហើយដែលជាគំនិតដែលមានកម្រិត (មានដែនកំណត់) របស់យើង ដែលឃើញថា ការស្វែងយល់ពីគំនិតនៃភាពមិនចេះចប់ចេះហើយគ្មានកម្រិត ឬ គ្មានដែនកំណត់ គឺមិនអាចទៅរួចនោះទេ។ ការពិត គឺថាភាពអស់កល្បជានិច្ច គឺជាទំនាក់ទំនងដ៏គ្មានព្រំដែនរបស់ព្រះជាម្ចាស់ជាមួយនឹងពេលវេលា។

២. *តើអ្នកណាបានរស់នៅក្នុងភាពអស់កល្បជានិច្ច?*

មនុស្ស និង ទេវតាគឺជាភាវៈដែលព្រះជាម្ចាស់បានបង្កើតមក ប៉ុន្តែមានតែទ្រង់មួយប៉ុណ្ណោះ ជាព្រះដែលគ្មានទីចាប់ផ្តើម។ ដូច្នេះ មានតែទ្រង់ប៉ុណ្ណោះដែលអាចគង់នៅក្នុងភាពអស់កល្បជានិច្ចបាន។ យើងមានអតីតកាល មានបច្ចុប្បន្នកាល និង អនាគតកាល ប៉ុន្តែព្រះជាម្ចាស់គង់នៅតែក្នុងបច្ចុប្បន្នកាលតែប៉ុណ្ណោះ។ ទាំងអតីតកាល និង អនាគតកាលគឺដូចជា *ពេលឥឡូវនេះ* សម្រាប់ទ្រង់។

ព្រះជាម្ចាស់គឺជាភាពអស់កល្បជានិច្ចនៅក្នុងរបៀបពីរយ៉ាង៖ ទី១) ទ្រង់មិនដែលមានការចាប់បដិសន្ធិ អ្វីឡើយ ទ្រង់មានព្រះវត្តមានតាំងពីដើមមក (គម្ពីរទំនុកតម្កើង ៩០:២) ។ ទី២ អត្ថិភាពរបស់ទ្រង់នឹងគ្មានទីបញ្ចប់ឡើយ (គម្ពីរទុតិយកថា ៣២:៤០ គម្ពីរទំនុកតម្កើង ១០២:២៧) ។ ដោយព្រះជាម្ចាស់ជាភាពអស់កល្បជានិច្ច ទ្រង់គ្មានវិវឌ្ឍទៅតាមពេលវេលានោះទេ។

៣. *តើយើងអាចយល់ពីគំនិតដែលថាព្រះជាម្ចាស់ជាភាពអស់កល្បជានិច្ចបានយ៉ាងដូចម្តេច?*

ក្រៅពីការយោងតាមបទគម្ពីរ យើងអាចធ្វើការសន្និដ្ឋានថា ព្រះជាម្ចាស់តែងតែមានព្រះវត្តមាន បានព្រោះតែមានគំនិតបែបតក្កវិជ្ជា។ មនុស្សគ្រប់គ្នាដឹងថា របស់មួយមិនអាចកើតឡើងចេញពីភាពទទេនោះ

ទេ។ សុញ្ញាអាកាស មិនអាចបង្កើតបានរបស់អ្វីមួយឡើយ។ ដូច្នេះ ប្រសិនបើនៅទីចាប់ផ្តើមនៃចក្រវាឡ គ្មានអ្វីទាល់តែសោះ និងប្រសិនបើមានតែសុញ្ញាអាកាសប៉ុណ្ណោះ អ៊ីចឹងចក្រវាឡទាំងមូលនឹងនៅមានតែប៉ុននោះទេ។ ប៉ុន្តែដោយហេតុតែ នៅពេលដែលយើងសង្កេតមើលទៅចក្រវាឡទាំងមូលដែលនៅជុំវិញយើង យើងក៏ត្រូវតែទទួលស្គាល់ ដោយផ្អែកលើតក្កភាពទៅលើការសន្និដ្ឋានដែលថា មានរបស់ម្យ៉ាងនៅអតីតកាល មិនដែលមានទីចាប់ផ្តើមនោះទេ ហើយរបស់នោះមានវត្តមានតាំងពីដើមមក។ *របស់ម្យ៉ាង* នោះគឺជាព្រះជាម្ចាស់!

ភាពអស់កល្បរបសព្រះជាម្ចាស់ គឺត្រូវបានបង្ហាញឲ្យឃើញ នៅពាសពេញបទគម្ពីរ។ ព្រះជាម្ចាស់ត្រូវបានបទគម្ពីរថ្វាយនាមថា ព្រះដ៏គង់នៅអស់កល្បជានិច្ច (គម្ពីរលោកុប្បត្តិ ២១:៣៣)។ អ្នកនិពន្ធ បានថ្លែងថា "ព្រះអង្គជាព្រះជាម្ចាស់តាំងពីអស់កល្បរៀងមក" (គម្ពីរទំនុកតម្កើង ៩០:២) ហើយថ្លែងថា "ព្រះអង្គនៅតែដដែល ព្រះជន្មាយុរបស់ព្រះអង្គគ្មានទីបញ្ចប់ទេ" (គម្ពីរទំនុកតម្កើង ១០២:២៧)ពាក្យពេចន៍ដ៏គួរឲ្យជំរុញចិត្តរបស់លោកអេសាយបានចែងថា ព្រះជាម្ចាស់គឺជាព្រះតែមួយអង្គគត់ "ដែលគង់នៅអស់កល្បជានិច្ច" (គម្ពីរអេសាយ ៥៧:១៥) ក្នុងពេលជាមួយគ្នា លោកប៉ូលអះអាងប្រាប់លោកធីម៉ូថេថា ព្រះជាម្ចាស់តែមួយគត់ ជាប្រភពនៃភាពអមតៈ (គម្ពីរ១ធីម៉ូថេ ៦:១៦)។

## *លំហាត់អនុវត្តន៍*

១១ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខចម្លើយត្រឹមត្រូវ។

ក) ភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ បានផ្តល់ឲ្យយើងនូវទំនុកចិត្ត ដែលដឹងថាព្រះមួយអង្គដែលយើងជឿនឹងមិនបាត់ទៅណាឡើយ។

ខ) ភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ លើកទឹកចិត្តយើង នៅពេលយើងមានការលំបាក។ យើងដឹងថាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលតែងតែស្ថិតស្ថេរនៅ នឹងបន្តស្ថិតស្ថេរនៅជារៀងរហូត។ បំណងព្រះហឫទ័យទាំងនេះ រួមបញ្ចូលទាំងបំណងព្រះហឫទ័យដែលទាក់ទងនឹងជីវិតរបស់យើងផ្ទាល់ផងដែរ។

គ) ការយល់ដឹងអំពីភាពគ្មានដែនកំណត់របស់ព្រះជាម្ចាស់ ដោយធៀបជាមួយនឹងពេលវេលា ធ្វើឲ្យយើងដឹងថាការសម្រេចចិត្តផ្ទាល់ខ្លួនរបស់យើង គឺមិនសំខាន់នោះទេ ព្រោះការទាំងនោះគឺផ្អែកតែទៅលើពេលវេលាតែប៉ុណ្ណោះ។

# ព្រះជាម្ចាស់ទ្រង់ខ្ជាប់ខ្ជួន (មិនប្រែប្រួល)

**វត្ថុបំណងទី៦.** *ប្រាប់អំពីអត្ថន័យនៃភាពមិនចេះប្រែប្រួលរបស់ព្រះជាម្ចាស់ សម្រាប់អ្នកទៅតាមការយល់ដឹង និង បទពិសោធន៍ជាគ្រិស្តបរិស័ទរបស់អ្នក។*

យើងរាល់គ្នាមានកំហុសដែលត្រូវការការកែប្រែ ឬ ការកែតម្រូវ ប៉ុន្តែព្រះជាម្ចាស់គឺមិនមានកំហុសអ្វីនោះទេ។ ទ្រង់គឺល្អឥតខ្ចោះ។ទ្រង់មិនត្រូវការអ្វីមួយមកបំពេញលក្ខណសម្បត្តិ ឬ គុណលក្ខណៈរបស់ទ្រង់នោះទេ។ ទ្រង់គឺល្អឥតខ្ចោះ គ្រប់ផ្នែកទាំងអស់។

# លំហាត់អនុវត្តន៍

១២ ចូរអានបទគម្ពីរខាងក្រោម ហើយធ្វើការបំពេញប្រយោគ។

ក) នៅក្នុងគម្ពីរទំនុកតម្កើង ១០២:២៥-២៧ ............................................ដែលមិនប្រែប្រួលរបស់យើងគឺផ្ទុយជាមួយនឹង...................................................................ដែលតែងតែប្រែប្រួល។

ខ) គម្ពីរអេសាយ ៤៦:៩-១០ គម្ពីរទំនុកតម្កើង៣៣:១១ និងគម្ពីរទំនុកតម្កើង ១១៩:១៦០ បង្ហាញថា ព្រះជាម្ចាស់គឺមិនប្រែប្រួលសោះឡើយ ទៅលើ................................................................... និង ..............................................................................................របស់ទ្រង់។

គ) គម្ពីរម៉ាឡាគី ៣:៦ បញ្ជាក់ថា ដោយព្រោះតែព្រះជាម្ចាស់មិនដែលផ្លាស់ប្តូរ ទ្រង់នឹងមានព្រះហឫទ័យមេត្តាករុណាទៅលើកូនចៅរបស់លោកយ៉ាកុប ដើម្បីកុំឲ្យពួកគេត្រូវបាន.................. .........................................................................។

ឃ) គម្ពីរទំនុកតម្កើង ១០៣:១៧ និយាយអំពី..................................និង .................................... ដែលមិនប្រែប្រួលរបស់ព្រះជាម្ចាស់។

បទគម្ពីរដែលមានចែងអំពីភាពខ្ជាប់ខ្ជួន ឬ និស្ស័យមិនប្រែប្រួលរបស់ព្រះជាម្ចាស់ បង្រៀនយើងអំពីគោលការណ៍ដ៏ច្បាស់លាស់អំពីព្រះជាម្ចាស់ដែលយើងបម្រើ។ លោក ធាសិន (Thiessen) [1] បង្ហាញអំពីគោលការណ៍ទាំងនេះ (១៩៧៩, ៨៣) ហើយយើងនឹងរៀបរាប់គោលការណ៍ទាំងនេះ ដើម្បីជួយឲ្យអ្នកឃើញកាន់តែច្បាស់ថែមទៀតៈ

១. ដោយព្រះជាម្ចាស់ទ្រង់គ្មានទីបញ្ចប់ កើតឡើងដោយអង្គឯង និង ឯករាជ្យ ទ្រង់គឺលើសផុតពីបុព្វហេតុ និង លទ្ធភាពនៃការប្រែប្រួល។

២. ព្រះជាម្ចាស់មិនអាចត្រូវ ដំឡើង ឬ បញ្ចុះបាននោះទេ ហើយទ្រង់ក៏មិនត្រូវបានដាក់ឲ្យរងការអភិវឌ្ឍបន្ថែមទៀតផងដែរ។

៣. ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ មិនអាចកើនកាន់តែច្រើនឡើង ឬ ចុះកាន់តែតិចជាងនេះឡើយ ហើយទ្រង់មិនអាចមានព្រះប្រាជ្ញាញាណជាងនេះ ឬ វិសុទ្ធជាងនេះឡើងដែរ។

៤. ព្រះជាម្ចាស់ មិនអាចកាន់តែយុត្តិធម៌ មានក្តីមេត្តាករុណា និង ប្រកបដោយក្តីស្រឡាញ់ជាងអ្វីដែលទ្រង់មានពីមុន ឬ នឹងមាននៅថ្ងៃអនាគតផងដែរ។

៥. ទ្រង់មិនអាចផ្លាស់ប្តូរទំនាក់ទំនងរវាងទ្រង់ជាមួយមនុស្សបាននោះទេ ។ ទ្រង់បំពេញព្រះរាជ្យកិច្ចដោយផ្អែកទៅតាមគោលការណ៍ដ៏អស់កល្បដែលមិនអាចត្រូវ កែប្រែទៅតាមការផ្លាស់ប្តូរប្រចាំថ្ងៃនោះទេ។

ដោយសារតែព្រះជាម្ចាស់ មិនប្រែប្រួល យើងអាចផ្ញើជីវិតរបស់យើងទាំងស្រុងទៅលើទ្រង់ដូចដែលយើងបានពឹងផ្អែកទៅលើព្រះបន្ទូលរបស់ទ្រង់ដែរ។ យើងអាចប្រឈមមុខជាមួយនឹងស្ថានភាពនៅក្នុងជីវិតគ្រប់ទាំងអស់ ប្រកបដោយទំនុកចិត្ត ដោយដឹងច្បាស់ថា ទ្រង់ធ្វើកិច្ចការគ្រប់បែបយ៉ាងគឺដើម្បីផលល្អរបស់យើង (គម្ពីររ៉ូម៨:២៨)។

អ្នកប្រហែលជាបានកត់សំគាល់ពីបទគម្ពីរ ដូចជាគម្ពីរជនគណនា ២៣:១៩និង គម្ពីរ ១សាំយូអែល ១៥:២៩ ដែលបានថ្លែងថា ព្រះជាម្ចាស់មិនផ្លាស់ប្តូរព្រះតម្រិះរបស់ព្រះអង្គឡើយ ហើយបទគម្ពីរផ្សេងៗទៀតបែរជាថ្លែងថាទ្រង់ បានបន្ធូរបន្ថយ ឬ សោកស្តាយចំពោះរឿងអ្វីមួយដែលទ្រង់បានធ្វើ (គម្ពីរ១សាំយូអែល ១៥:១១ គម្ពីរយ៉ូណាស ៣:៩-១០) ។ ឥរិយាបថរបស់ព្រះជាម្ចាស់នេះ មិនបង្ហាញឲ្យឃើញពីការផ្លាស់ប្តូរជាមូលដ្ឋានទៅលើលក្ខណសម្បត្តិ ឬ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ ។ ទ្រង់តែងតែមិនគាប់ព្រះហឫទ័យចំពោះអំពើបាប ហើយទ្រង់តែងតែគាប់ព្រះហឫទ័យចំពោះមនុស្សមានបាប។ ឥរិយាបថនេះ គឺនៅតែជាការពិត មិនថាមុនពេល ឬ ក្រោយពេលមនុស្សមានបាបធ្វើការលន់តួនោះទេ។ ទោះជាយ៉ាងណា ព្រះជាម្ចាស់អាចនឹងផ្លាស់ប្តូរអាកប្បកិរិយារបស់ទ្រង់ទៅតាមការជាក់ស្តែងនៃការផ្លាស់ប្តូររបស់មនុស្ស។

---

1 Thiessen, Henry C. Lectures in Systematic Theology. Grand Rapids, MI; Eerdmans, 1979

ឧទាហរណ៍មួយសម្រាប់ការនេះ យើងឃើញថាឥរិយាបថរបស់ព្រះជាម្ចាស់ទៅលើអំពើបាបរបស់សាសន៍អ៊ីស្រាអែល គ្មានការប្រែប្រួលនោះទេ។ ទ្រង់មិនសព្វព្រះហឫទ័យចំពោះអំពើបាបរបស់សាសន៍នេះឡើយ។ ដោយសារប្រជារាស្ត្ររបស់ទ្រង់នៅតែចចេសបន្តប្រព្រឹត្តិអំពើបាប ពួកគេបានទទួលការដាក់ទោសសម្រាប់អំពើបាបរបស់ពួកគេ។ ទោះជាយ៉ាងណា នៅពេលដែលពួកគេបានលន់តួ ហើយផ្តាច់ខ្លួនចេញពីការប្រព្រឹត្តិអំពើបាបរបស់ពួកគេ អាកប្បកិរិយារបស់ព្រះជាម្ចាស់ទៅលើពួកគេក៏បានផ្លាស់ប្តូរផងដែរ។

មានមនុស្សម្នាក់បាននិយាយថា ព្រះអាទិត្យមិនដែលបង្ហាញភាពលំអៀង ឬ ការប្រែប្រួលនៅទៅលើការរំលាយក្រមួន និង ធ្វើឲ្យដីឥដ្ឋរឹងនោះទេ ដ្បិតការផ្លាស់ប្តូគឺមិនមែននៅក្នុងព្រះអាទិត្យនោះឡើយ តែវាស្រេចទៅតាមវត្ថុធាតុដែលព្រះអាទិត្យចាំងជះរស្មីទៅលើតែប៉ុណ្ណោះ។ យើងអាចផ្អែកលើភាពខ្ជាប់ខ្ជួននៃបំណងព្រះហឫទ័យ ព្រះបន្ទូល និង និស្ស័យរបស់ព្រះជាម្ចាស់បាន។ ដូចដែលព្រះអាទិត្យរំលាយក្រមួន និងធ្វើឲ្យដីឥដ្ឋរឹង ភាពខ្ជាប់ខ្ជួនរបស់ព្រះជាម្ចាស់ធ្វើឡើងដើម្បីតែផលល្អរបស់អស់អ្នកដែលបានបន្ទន់ចិត្តដើម្បីជាការឆ្លើយតបដែលគាប់ព្រះហឫទ័យរបស់ទ្រង់ និង សម្រាប់កំទេច អស់អ្នកដែលមានដួងចិត្តមិនឆ្លើយតបគាប់ព្រះហឫទ័យទ្រង់ តែបែបជារឹងទទឹងទៅវិញ។

## ***លំហាត់អនុវត្តន៍***

---

១៣ ដើម្បីរំឭកពីគុណសម្បត្តិនៃនិស្ស័យរបស់ព្រះជាម្ចាស់ ដែលមានបកស្រាយនៅក្នុងផ្នែកមួយនេះ ចូរផ្គូផ្គង់គុណសម្បត្តិនីមួយៗ (ខាងស្តាំ) ទៅនឹងការរៀបរាប់របស់គុណសម្បត្តិនោះ (ខាងឆ្វេង)។

.........ក) មានសភាពជាសារធាតុ និង សមាសភាពតែមួយ ១) បុគ្គលិកលក្ខណៈ

.........ខ) មិនចេះចប់មិនចេះហើយ គ្មានទីចាប់ផ្តើម ឬទីបញ្ចប់ ២) ភាពជាវិញ្ញាណ

.........គ) មានភាពគ្មានដែនកំណត់ទៅលើទម្រង់ ឬ រូបធាតុដើម។
.........ឃ) ពហុភាពនៃបុគ្គល (អង្គ)។
.........ង) ភាពដូចគ្នាទៅលើបំណង ពាក្យពេចន៍ និង លក្ខណសម្បត្តិ។
.........ច) ភាពដែលអាចគិត ទទួលអារម្មណ៍ និង សម្រេចចិត្តបាន។

៣) ភាពរួបរួម
៤) ព្រះត្រៃឯក
៥) ភាពអស់កល្បជានិច្ច
៦) ភាពខ្ជាប់ខ្ជួន

# ខ. គុណលក្ខណៈធម្មជាតិរបស់ព្រះជាម្ចាស់

**វត្ថុបំណងទី៧.** *រៀបរាប់ និង កំណត់ន័យគុណលក្ខណៈរបស់ព្រះជាម្ចាស់។*

យើងហៅអស់អ្នកដែលមានជំនាញទៅលើការសិក្សាអំពីព្រះជាម្ចាស់ថា *សាសនវិទូ។* អ្នក និង ខ្ញុំ ប្រហែលជាមិនអាចចាត់ទុកជាសាសនវិទូបាននោះទេ ប៉ុន្តែយើងមានសិទ្ធិដើម្បីសិក្សា និង វិភាគអំពីគោលលទ្ធិ ឬសេចក្ដីបង្រៀនអំពីព្រះជាម្ចាស់ ដើម្បីឲ្យយើងអាចយល់ពីទ្រង់កាន់តែច្បាស់ និងស្រឡាញ់ទ្រង់កាន់តែច្រើនឡើង។ ជារឿងដ៏សំខាន់ ដែលយើងមិនត្រូវពិចារណាតែទៅលើនិស្ស័យរបស់ទ្រង់នោះទេ ប៉ុន្តែយើងត្រូវពិចារណាអំពីលក្ខណសម្បត្តិរបស់ទ្រង់ផងដែរ នៅក្នុងដំណើរផ្សងព្រេងដើម្បីស្គាល់ទ្រង់កាន់តែប្រសើរមួយនេះ។ សាសនវិទូបានហៅលក្ខណសម្បត្តិទាំងនេះថា *គុណលក្ខណៈ (attributes)* ។ គុណលក្ខណៈសាមញ្ញ គឺសំដៅទៅលើគុណសម្បត្តិទាំងឡាយណាដែលទាក់ទងនឹង ឬ រៀបរាប់អំពីនរណាម្នាក់ ឬ អ្វីមួយ ហើយនៅក្នុងករណីនេះ គឺព្រះជាម្ចាស់នោះឯង។ គុណលក្ខណៈរបស់ព្រះជាម្ចាស់ បកស្រាយពីមូលហេតុដែលទ្រង់ធ្វើអ្វីដែលទ្រង់ធ្វើ ដូច្នេះយើងអាចដឹងពីអ្វីដែលយើងរំពឹងទុកពីទ្រង់។ គុណលក្ខណៈរបស់ព្រះជាម្ចាស់រួមមាន សព្វានុភាព សព្វត្ថិភាព សព្វញ្ញូតញាណ និង ព្រះប្រាជ្ញាញាណ។ ដំបូងយើងនឹងពិចារណាទៅលើ សព្វានុភាពរបស់ព្រះជាម្ចាស់ជាមុនសិន។

## សព្វានុភាពរបស់ព្រះជាម្ចាស់

ភរិយារបស់លោកអប្រាហាំ លោកស្រីសារ៉ាយ បានធ្វើដំណើរជាច្រើនលើកច្រើនសានៅក្នុងជីវិតរបស់លោកស្រី។ លោកស្រីបានឃើញព្រះយេហូវ៉ាធ្វើការអស្ចារ្យ និង គួរឲ្យស្ញប់ស្ញែងជាច្រើនសម្រាប់ប្ដីរបស់លោកស្រី និង លោកស្រីផ្ទាល់។ លោកស្រីមានសម្រស់ដែលអាចយកឈ្នះការប្រកួតប្រជែងភាពស្រស់ស្អាតបានកាលលោកស្រីនៅជាកូនក្រមុំទើបរៀបការ ប៉ុន្តែមកដល់ពេលនេះ ស្ត្រីចំណាស់មានស្បែកជ្រួញម្នាក់នេះ អង្គុយចុះក៏ត្រូវប្រុងប្រយ័ត្នដែរ។ លោកស្រីបានសើច នៅពេលដែលលោកស្រីបានឮថាមានបុរសបីនាក់បានប្រាប់ប្ដីលោកស្រីថា លោកស្រីនឹងមានផ្ទៃពោះឆាប់ៗ។ មិនអាចទៅរួចទេ! តើអ្នកគួរតែបន្ទោសលោកស្រីសារ៉ាយចំពោះការដែលលោកស្រីសើចនោះដែរឬទេ? ប៉ុន្តែបុរសទាំងបីដែលមកពីស្ថានបរមសុខនោះបានសួរថា៖ "តើមានការអ្វីអស្ចារ្យពេកដែលព្រះអម្ចាស់ធ្វើមិនកើត?" (គម្ពីរលោកុប្បត្តិ ១៨:១-១៥)។

តើលក្ខណសម្បត្តិជាព្រះ ណាមួយដែលព្រះអម្ចាស់បានរំឭកទៅដល់លោកអប្រាហាំ និង លោកស្រីសារ៉ាយ? សព្វានុភាពរបស់ទ្រង់ ជាការពិតដែលថាទ្រង់មានគ្រប់ព្រះចេស្ដា ឬ គ្រប់ឫទ្ធានុភាព។ ទ្រង់

អាចធ្វើអ្វីៗគ្រប់បែបយ៉ាង! ឫទ្ធានុភាពដ៏ពេញបរិបូរណ៍របស់ព្រះជាម្ចាស់មួយនេះបានបង្ហាញឲ្យយើងឃើញនៅក្នុងបទគម្ពីរ ទាក់ទងនឹង៖

១. ការបង្កើត (គម្ពីរលោកុប្បត្តិ ១:១)
២. ការទ្រទ្រង់របស់គ្រប់យ៉ាងដោយព្រះបន្ទូលដ៏មានឫទ្ធានុភាពរបស់ទ្រង់ (គម្ពីរហេប្រឺ១:៣)
៣. ការប្រោសលោះមនុស្ស (គម្ពីរលូកា ១:៣៥, ៣៧)
៤. ការអស្ចារ្យ (គម្ពីរលូកា ៩:៤៣)
៥. ការសង្គ្រោះមនុស្សមានបាប (គម្ពីរ១កូរិនថូស ២:៥ គម្ពីរ២កូរិនថូស ៤:៧)
៦. ការសម្រេចបំណងព្រះហឫទ័យរបស់ព្រះអង្គសម្រាប់នគររបស់ព្រះអង្គ(គម្ពីរ១ពេត្រុស ១:៥)

យើងត្រូវតែចងចាំថា ទោះបីជាព្រះជាម្ចាស់មិនអាចធ្វើរឿងដែលមិនសមហេតុផល (រឿងដែលគួរឲ្យអស់សំណើច ឬ គ្មានហេតុផល) ដូចជាបង្កើតទឹកដែលស្ងួត ។ ទ្រង់ក៏មិនធ្វើអ្វីដែលមិនសមស្របទៅនឹងនិស្ស័យរបស់ទ្រង់ផងដែរ។

ការពិតមួយដែល មានភាពស្របទៅតាមនិស្ស័យរបស់ព្រះជាម្ចាស់គឺ ការពិតដែលថាទ្រង់អាចកំណត់ការប្រព្រឹត្តិទៅនៃឫទ្ធានុភាពរបស់ទ្រង់ ប្រសិនបើទ្រង់សព្វព្រះហឫទ័យ។ ជាឧទាហរណ៍ ព្រះជាម្ចាស់ប្រទានមនុស្សម្នាក់ៗ នូវសេរីភាពក្នុងការជ្រើសរើស រវាងទ្រង់នឹងសាតាំង។ ព្រះជាម្ចាស់មិនបង្ខិតបង្ខំមនុស្សឲ្យបម្រើទ្រង់ ទាស់នឹងឆន្ទៈផ្ទាល់ខ្លួនរបស់ពួកគេនោះទេ។ទ្រង់កំណត់អង្គទ្រង់ដើម្បីអនុញ្ញាតឲ្យមនុស្សធ្វើការសម្រេចចិត្តដោយខ្លួនឯង។

គម្ពីរយេរេមា ៣២:១៧ ថ្លែងទៅកាន់ ព្រះអម្ចាស់ថា៖ "ព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដីដោយមហិទ្ធិឫទ្ធិ និងព្រះបារមីរបស់ព្រះអង្គ។ តើមានការអស្ចារ្យអ្វីដែលព្រះអង្គធ្វើមិនកើត?" ក្រោយមកទៀតព្រះអម្ចាស់បានមានព្រះបន្ទូលសួរទៅកាន់លោកយេរេមាថា៖ "តើមានការអ្វីដែលពិបាកពេកដល់អញដែរឬ?"(ខ២៧ នៃគម្ពីរបកប្រែឆ្នាំ១៩៥៤)។ នៅពេលយើងយល់ពីឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៃយើងហើយ យើងមិនគួរមានភាពស្ទាក់ស្ទើរក្នុងការទៅសូមជំនួយពីទ្រង់ នៅក្នុងគ្រប់កាលៈទេសៈដែលយើងប្រឈមមុខម្តងទៀតឡើយ។

## លំហាត់អនុវត្តន៍

១៤ ចូរអានគម្ពីរនិក្ខមនំ៣:១១-១២ តើអ្វីជាពាក្យទាំងប្រាំម៉ាត់ដែលព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់លោកម៉ូសេដើម្បីរំឭកលោកពីសព្វានុភាពរបស់ទ្រង់?

..........................................................................................................................

# សព្វត្ថិតាពរបស់ព្រះជាម្ចាស់

ក្មេងតូចម្នាក់ចង់ធ្វើរឿងអាក្រក់មួយ ប៉ុន្តែគេសម្រេចចិត្តថា គេគួរតែចូលទៅក្រោមដំបូលផ្ទះដើម្បីធ្វើរឿងនោះ ដើម្បីនៅពេលដែលព្រះជាម្ចាស់ទតមើលពីលើស្ថានសួគ៌មក មិនឃើញអ្វីដែលគេកំពុងធ្វើ។ តើលក្ខណសម្បត្តិជាព្រះណាមួយដែលក្មេងតូចម្នាក់មិនបានដឹង? ការពិតដែលថាព្រះជាម្ចាស់គឺ សព្វត្ថិភាព មានន័យថា ទ្រង់គឺគង់នៅគ្រប់ទីកន្លែងគ្រប់ពេលវេលា។ អ្នកនិពន្ធបាននិយាយអំពីការនេះ នៅក្នុងគម្ពីរទំនុកតម្កើង ១៣៩:៧-១០៖

តើទូលបង្គំអាចទៅណាឆ្ងាយពីព្រះអង្គបាន? តើទូលបង្គំគេចចេញអោយឆ្ងាយពីព្រះភក្ត្ររបស់ព្រះអង្គដូចម្តេចបាន? បើទូលបង្គំឡើងទៅលើមេឃព្រះអង្គគង់នៅទីនោះបើទូលបង្គំទៅនៅស្ថានមនុស្សស្លាប់ក៏ព្រះអង្គនៅទីនោះដែរ។ ទោះបីទូលបង្គំពាក់ស្លាបហោះទៅកន្លែងព្រះអាទិត្យរះឬទោះបីទូលបង្គំទៅរស់នៅខាងនាយសមុទ្រក្តី ក៏ព្រះអង្គគង់នៅទីនោះ ដើម្បីដឹកនាំទូលបង្គំហើយជួយទូលបង្គំ ដោយព្រះបារមីរបស់ព្រះអង្គ។

សព្វត្ថិភាពរបស់ព្រះជាម្ចាស់មិនមែនមានន័យថា ទ្រង់មានទំនាក់ទំនងដូចគ្នានេះ ជាមួយមនុស្សគ្រប់គ្នានោះទេ។ ទ្រង់នឹងបង្ហាញអង្គទ្រង់ ទ្រង់នឹងប្រទានពរ និង លើកទឹកចិត្តអស់អ្នកណាដែលស្រឡាញ់ និង បម្រើទ្រង់ ប៉ុន្តែទ្រង់នឹងស្តីបន្ទោស និង ដាក់ទោសអ្នកណាដែលទាស់ប្រឆាំងនឹងទ្រង់ ។ ទ្រង់យាងមកនៅក្នុងព្យុះ ប៉ុន្តែទ្រង់នឹងមិនយ៉ាងដូច្នោះទេ ប្រសិនបើមានបុត្ររបស់ទ្រង់ពីរ ឬ បីនាក់ជុំគ្នាអធិស្ឋានដើម្បីទូលសូមការនាំផ្លូវមកពីទ្រង់ (គម្ពីរណាហ៊ូម ១:៣ គម្ពីរម៉ាថាយ១៨:២០)។

ការដឹងថាព្រះជាម្ចាស់តែងតែគង់នៅក្បែរ បានផ្តល់ឲ្យយើងនូវកម្លាំងចិត្តនៅពេលមានបញ្ហា ព្រោះយើងដឹងថាព្រះជាម្ចាស់នៅទីនោះដើម្បីផ្តល់កម្លាំង និង នាំផ្លូវយើង។ ការនេះក៏រំឭកយើងឲ្យមានការប្រុងប្រយ័ត្នជាមួយនឹងរបៀបដែលយើងរស់នៅ ព្រោះព្រះជាម្ចាស់ទតឃើញអ្វីៗគ្រប់បែបយ៉ាងដែលយើងធ្វើ មិនថាការល្អ ឬ ការអាក្រក់។ យើងមានទំនួលខុសត្រូវក្នុងការបម្រើព្រះជាម្ចាស់ ឲ្យបានដិតដល់នៅគ្រប់ទីកន្លែង និងនៅគ្រប់ពេលវេលា ដ្បិតទ្រង់គង់នៅគ្រប់កន្លែងទាំងនោះ។

យើងក៏គួរតែរំឭកខ្លួនឯងថា យើងមិនអាចប្រើប្រាស់អារម្មណ៍ផ្ទាល់ខ្លួនរបស់យើង ធ្វើជារង្វាស់សម្រាប់ព្រះវត្តមានរបស់ព្រះជាម្ចាស់នៅជាមួយយើងនោះឡើយ។ មិនថាយើងមានអារម្មណ៍បែបណា ព្រះជាម្ចាស់ក៏គង់នៅជាមួយយើង។ ឧបមាថា មានក្មេងស្រីម្នាក់កំពុងតែយំនៅក្នុងទីងងឹត ហើយម្តាយរបស់នាងប្រាប់នាងថា គាត់នៅជាមួយនាង។ ក្មេងស្រីនោះប្រហែលជាគិតថា នាងត្រូវតែមើលឃើញម្តាយរបស់នាងជាមុនសិនដើម្បីដឹងថាគាត់នៅទីនោះពិតមែន។ មិនថានាងមើលឃើញម្តាយរបស់នាង,ឬមិនឃើញ ក៏ការនោះមិនអាចផ្លាស់ប្តូរការពិតដែលថាម្តាយរបស់នាងគាត់នៅទីនោះយ៉ាងពិតប្រាកដបានដែរ។ ដូច្នេះជាមួយពួកយើងវិញ។ មិនថាយើងមាន*អារម្មណ៍ដឹង* ព្រះវត្តមានរបស់ព្រះជាម្ចាស់ ឬមិនដឹងក៏ដោយ ក៏ព្រះគម្ពីរបានប្រាប់យើងថាទ្រង់គង់នៅគ្រប់ទីកន្លែង។ គ្រាន់តែដឹងប៉ុណ្ណោះ គឺគ្រប់គ្រាន់សម្រាប់យើង ក្នុងរក្សានូវឥរិយាបថនៃការសសើរតម្កើង និង មានកម្លាំងចិត្តគ្រប់ពេលបានទៅ
ហើយ។

## *លំហាត់អនុវត្តន៍*

១៥ នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូរប្រាប់មូលហេតុពីរយ៉ាង ដែលការស្គាល់ពីសព្វត្តិភាពរបស់ព្រះជាម្ចាស់ ត្រូវតែមានឥទ្ធិពលមកលើរបៀបដែលយើងរស់នៅ។

# សព្វញ្ញុតញាណរបស់ព្រះជាម្ចាស់

បើយើងសិក្សាទៅមុខមួយជំហានពីសព្វត្តិភាពរបស់ព្រះជាម្ចាស់ យើងនឹងទៅដល់សព្វញ្ញុតរបស់ព្រះជាម្ចាស់ ដែលជាចំណេះដឹងរបស់ព្រះជាម្ចាស់អំពីអ្វីៗគ្រប់បែបយ៉ាង។ មនុស្សតែងតែខិតខំធ្វើការយ៉ាងខ្លាំងដើម្បីបកស្រាយការពិត។ នៅពេលដែលយើងសិក្សា ដើម្បីទទួលបានចំណេះដឹង យើងប្រមូលបានសេចក្ដីពិត ប៉ុន្តែមើលទៅហាក់បីដូចជា នៅពេលដែលយើងកាន់តែរៀន យើងកាន់តែដឹងថា យើងដឹងតែបន្តិចបន្តួចតែប៉ុណ្ណោះ។

ព្រះជាម្ចាស់គ្មានបញ្ហាដូចនេះទេ។ ទ្រង់ជ្រាបដឹងគ្រប់យ៉ាង។ អ្នកគ្រប់គ្រងនៃសាកលលោក ទ្រង់មានការត្រាស់ដឹងដ៏គ្មានដែនកំណត់។ ការពិតនេះ គឺជាការដែលយើងគ្មានថ្ងៃស្វែងយល់ពេញលេញនោះទេ ប៉ុន្តែវាគឺជាការចាំបាច់សម្រាប់ជំនឿរបស់យើង ទៅលើភាពឥតខ្ចោះរបស់ព្រះជាម្ចាស់។ ជាក់ស្ដែង ទ្រង់ច្បាស់ជាជ្រាបដឹងពីអ្វីគ្រប់យ៉ាងដែលជាក់លាក់ និង អ្វីគ្រប់យ៉ាងដែលអាចកើតឡើង។ បើពុំនោះទេ ទ្រង់មុខជាត្រូវរៀនអំពីរឿងដែលទ្រង់មិនជ្រាបដឹងពីមុនមកជាប់រហូត ហើយទ្រង់មុខជាត្រូវកែប្រែផែនការ និង បំណងព្រះហឫទ័យរបស់ទ្រង់ទៅតាមនោះ។

ដោយព្រះជាម្ចាស់ជ្រាបដឹងគ្រប់ការទាំងអស់ ទ្រង់អាចប្រាប់ពីអ្វីដែលនឹងកើតឡើងនាពេលអនាគត តាំងពីមុនការនោះកើតឡើងទៅទៀត។ ដូច្នេះ យើងឃើញពីហេតុការណ៍ជាច្រើនដែលមានប្រាប់ទុកមុននៅក្នុងបទគម្ពីរ។ នេះមិនមែនមានន័យថាព្រះដ៏អស់កល្បជានិច្ច ទ្រង់ធ្វើការសម្រេចព្រះទ័យអំពីអ្វីដែលនឹងកើតឡើងមកលើយើងនោះទេ។ ទ្រង់គ្រាន់តែដឹងពីអ្វីដែលនឹងជាការសម្រេចចិត្តរបស់យើងមុនពេលដែលយើងធ្វើការសម្រេចចិត្តនោះតែប៉ុណ្ណោះ។ ដោយសារទ្រង់ទតឃើញជាមុន ទ្រង់អាចមានព្រះបន្ទូលប្រាប់ទុកមុន នូវអ្វីៗដែលនឹងកើតឡើងនាពេលអនាគត។ ការដែលទ្រង់អាចប្រាប់មកនេះ មិនមែនមានន័យថាទ្រង់*កំណត់ទុកមុន* ឬ ធ្វើការសម្រេចជាមុន ទៅលើអ្វីដែលអាចនឹងកើតឡើងនោះទេ។

ការពិតដែលថា ព្រះជាម្ចាស់ជ្រាបដឹងគ្រប់អ្វីៗទាំងអស់នេះ គួរតែជាការពង្រឹងកម្លាំងសម្រាប់ជំនឿរបស់យើង នៅពេលណាដែលយើងស្ថិតនៅក្នុងបញ្ហាដ៏ធ្ងន់ធ្ងរមួយ ដ្បិតទ្រង់ជ្រាប់ដឹងច្រើនជាងអ្វីដែលយើងបានដឹងអំពីបញ្ហារបស់យើង។ ទ្រង់ជ្រាបអំពីមូលហេតុ និងអ្វីដែលនឹងកើតឡើងជាមួយនឹងដំណោះស្រាយនីមួយៗដែលយើងអាចគិតឃើញ។ យើងអាចទទួលបានការធានាដ៏អស្ចារ្យមួយ ចេញពីការពិតមួយនេះ នៅពេលដែលយើងស្វែងរកការដឹកនាំរបស់ទ្រង់ ដើម្បីរកដំណោះស្រាយសម្រាប់បញ្ហារបស់យើង។

## *លំហាត់អនុវត្តន៍*

១៦ ចូរអានគម្ពីរទំនុកតម្កើង ១៣៩:១-១៩ ហើយបំពេញប្រយោគទាំងនេះ។

ក) ខទី........ ថ្លែងអំពីសព្វញ្ញូណញាណរបស់ព្រះជាម្ចាស់។

ខ) ខទី.........ថ្លែងអំពីសព្វានុភាពរបស់ព្រះជាម្ចាស់។

គ) ខទី........ថ្លែងអំពីសព្វត្ថិភាពរបស់ព្រះជាម្ចាស់។

១៧ តើប្រយោគណាមួយត្រឹមត្រូវ ទាក់ទងនឹងនឹងសព្វញ្ញូណញាណរបស់ព្រះជាម្ចាស់?

ក) ដោយសារព្រះជាម្ចាស់ជ្រាបដឹងការសម្រេចចិត្តដែលខ្ញុំនឹងធ្វើ នោះការសម្រេចចិត្តទាំងអស់របស់ខ្ញុំគឺជាការសម្រេចព្រះទ័យរបស់ទ្រង់។

ខ) ការដឹងថាព្រះជាម្ចាស់ជ្រាបគ្រប់អ្វីៗទាំងអស់ នឹងនាំឲ្យខ្ញុំឲ្យចូលទៅកាន់ទ្រង់ ដើម្បីទទួលបានការនាំផ្លូវពីទ្រង់ នៅពេលដែលខ្ញុំត្រូវធ្វើការសម្រេចអ្វីមួយ។

គ) ការប្រាប់ទុកមុនមានន័យថា ការកំណត់ទុកមុន។

ឃ) ប្រសិនបើព្រះជាម្ចាស់មិនជ្រាបដឹងគ្រប់ការនោះទេ ទ្រង់នឹងមិនសូវមានភាពឥតខ្ចោះនោះទេ។

ង) សព្វញ្ញូណញាណមានន័យថា ការដឹងគ្រប់យ៉ាងដែលត្រូវដឹង រួមទាំងចំណេះដឹងឥតខ្ចោះអំពីអតីតកាល បច្ចុប្បន្នកាល និង អនាគតកាល។

## ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់

អ្នកវិទ្យាសាស្ត្រជាច្រើននាក់ ដឹងអំពីការពិតជាច្រើន ប៉ុន្តែចំណេះដឹងអំពីពិភពលោកទាំងអស់នោះមិនបានដោះស្រាយបញ្ហាក្នុងសង្គមនោះទេ។ មនុស្សគ្មានប្រាជ្ញាសមស្របដែលអាចឲ្យពួកគេដឹងអំពីរបៀបប្រើប្រាស់ចំណេះដឹងដែលពួកគេមានដើម្បីដោះស្រាយបញ្ហា ទៅតាមរបៀបមួយដែលអនុញ្ញាតឲ្យមនុស្សគ្រប់រូបរស់នៅរួមគ្នាប្រកបដោយសុខសន្តិភាព និង ភាពរីកចម្រើនបានឡើយ។

ប្រាជ្ញាមិនដូចជាចំណេះដឹងនោះទេ។ ដើម្បីទទួលបានប្រាជ្ញា យើងត្រូវស្វែងរកតាមរយៈចំណេះដឹងដើម្បីឲ្យឃើញពីគោលបំណងដ៏ខ្ពស់បំផុត ហើយប្រើប្រាស់ទៅតាមរបៀបមួយដែលល្អប្រសើរបំផុត។ ដោយសារព្រះជាម្ចាស់ ទ្រង់មានប្រាជ្ញាគ្រប់ទាំងអស់ ទ្រង់ធ្វើការគ្រប់បែបយ៉ាងបានយ៉ាងល្អ។ ដោយប្រើព្រះប្រាជ្ញាញាណដ៏ឥតខ្ចោះរបស់ទ្រង់ ព្រះជាម្ចាស់បានប្រទានព្រះបន្ទូលរបស់ទ្រង់មកឲ្យយើងនៅក្នុងព្រះគម្ពីរ ដើម្បីនាំផ្លូវយើងក្នុងគ្រប់ការទាំងអស់ដែលយើងធ្វើ។ ប្រសិនបើយើងរស់នៅ ស្របតាមការដឹកនាំរបស់ទ្រង់ ដូចមានកត់ត្រាទុកនៅក្នុងព្រះបន្ទូលរបស់ទ្រង់ យើងនឹងទទួលបានប្រយោជន៍ ពីប្រាជ្ញារបស់ទ្រង់ និង ទទួលបានព្រះពរពីទ្រង់។

ពេលខ្លះ យើងមិនអាចមើលឃើញពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ក្នុងការដែលទ្រង់អនុញ្ញាតឲ្យមានរឿងអ្វីមួយកើតឡើងនៅក្នុងជីវិតរបស់យើងបាននោះទេ។ ដំបូង យើងត្រូវចាំថា ព្រះជាម្ចាស់អនុញ្ញាតឲ្យយើងធ្វើការសម្រេចចិត្តផ្ទាល់ខ្លួន ហើយប្រសិនបើជម្រើសទាំងនោះមិនស្របទៅតាម

បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ យើងអាចនឹងនាំបញ្ហាមកដាក់លើខ្លួនឯង។ ដូចគ្នាដែរ យើងត្រូវចាំថា យើងរស់នៅក្នុងលោកីយ៍ដែលពេញដោយអំពើបាប ហើយមានពេលខ្លះ មិនថាគ្រិស្តបរិស័ទ ឬ អ្នកមិនមែនគ្រិស្តបរិស័ទ អាចនឹងក្លាយជាជនរងគ្រោះពីគ្រោះមហន្តរាយ ឬ ទង្វើអាក្រក់របស់អ្នកដទៃ ក្នុងលោកីយ៍ដែលបានខូចបង់ដោយអំពើបាបមួយនេះ។ ព្រះជាម្ចាស់គ្មានកាតព្វកិច្ចយាងមកឯយើងរាល់គ្នា ហើយបកស្រាយមូលហេតុដែលអ្វីគ្រប់យ៉ាងកើតឡើងតាមរបៀបដែលវាកើតឡើងនោះទេ។ ទ្រង់ប្រហែលជាអនុញ្ញាតឲ្យរឿងរ៉ាវកើតឡើងដោយសារមូលហេតុមួយដែលយើងមិនដឹងសោះ ប៉ុន្តែដូចដែលគម្ពីរ១យ៉ូហាន ៤:១៨ ថ្លែងថា "សេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណៈ បណ្តេញការភ័យខ្លាចអោយចេញផុតទៅ"។ យើងអាចជឿទុកចិត្តព្រះជាម្ចាស់យ៉ាងពេញលេញ នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ដោយដឹងថាតាមរយៈព្រះប្រាជ្ញាញាណ ទ្រង់នឹងធ្វើការគ្រប់បែបយ៉ាងដើម្បីផលល្អរបស់យើង និង ដើម្បីសិរីរុងរឿងរបស់ទ្រង់ (គម្ពីររ៉ូម ៨:២៨)។

បទគម្ពីរដូចជាគម្ពីរទំនុកតម្កើង ១០៤:២៤-៣០ និងគម្ពីរយេរេមា ១០:១២ បានរំឮកយើងថា យើងអាចឃើញពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់តាមរយៈស្នាព្រះហស្តរបស់ទ្រង់។ ការសម្រេចបាននូវរចនាបទដ៏ស្មុគស្មាញរបស់ធម្មជាតិ គឺទាមទារឲ្យមានការបង្កើតយ៉ាងប៉ិនប្រសព្វ។ នៅពេលដែលខ្ញុំពិនិត្យមើលទៅស្លាបសត្វបក្សីមួយ ខ្ញុំគ្មានពាក្យអ្វីនិយាយបានទេ។ គ្រប់ផ្នែកដ៏តូចល្អិត គឺត្រូវបានរចនាឡើងដើម្បីតួនាទីពិសេសមួយ មិនថាការហោះហើរ ឬ ការការពារបក្សីនោះឲ្យផុតពីអាកាសធាតុនោះទេ។ បើនៅពេលដែលខ្ញុំពិនិត្យមើលទៅលើគ្រោងឆ្អឹងរបស់សត្វបក្សី ខ្ញុំឃើញថាឆ្អឹងធំៗគឺមានប្រហោង ហើយពេញដោយខ្យល់ លក្ខណៈនេះធ្វើឲ្យសត្វតូចនេះអាចហោះទៅលើអាកាសបាន។ កូនចៅជំនាន់ក្រោយរបស់បក្សីនោះ នឹងមានរចនាបទដូចគ្នានោះដែរ។ នេះគឺជាឧទាហរណ៍ដ៏តូចមួយនៃព្រះប្រាជ្ញាញាណដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៃយើង។

ខ្ញុំមានពរណាស់ នៅពេលដែលខ្ញុំចាំថាព្រះជាម្ចាស់ក៏បានប្រទានព្រះប្រាជ្ញាញាណរបស់ទ្រង់ មកឲ្យយើងនៅពេលដែលយើងត្រូវការផងដែរ។ អ្វីដែលសំខាន់គឺមិនមែនអ្វីដែលយើងប្រឈមមុខនៅថ្ងៃនេះ ថ្ងៃស្អែក សប្តាហ៍ក្រោយ ឬខែក្រោយនោះទេ។ គម្ពីរយ៉ាកុប១:៥បានប្រាប់យើងកុំឲ្យសង្ស័យ ប៉ុន្តែត្រូវទូលសូមប្រាជ្ញា ដ្បិតព្រះជាម្ចាស់ទ្រង់មានក្តីសប្បុរស និង ក្តីមេត្តា ក្នុងការប្រទានប្រាជ្ញានោះមកឲ្យប្រជារាស្រ្តរបស់ទ្រង់។

## *លំហាត់អនុវត្តន៏*

---

១៨ ដោយផ្អែកទៅលើការពិភាក្សារបស់យើងអំពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ តើប្រយោគណាខ្លះដែលនៅខាងក្រោមនេះ ជាឧទាហរណ៍ល្អអំពីព្រះប្រាជ្ញាញាណរបស់ទ្រង់?

ក) ប្រសិនបើខ្ញុំមានការចំណាយដែលមិនបានព្រៀងទុកមុន ហើយមិនដឹងធ្វើយ៉ាងណាដើម្បីរៀបចំផែនការ ដោះស្រាយបញ្ហានោះទេ ខ្ញុំអាចទូលសូមព្រះជាម្ចាស់ឲ្យទ្រង់ដឹកនាំ ហើយដឹងថាទ្រង់អាចប្រទានប្រាជ្ញាដែលខ្ញុំត្រូវការដើម្បីដោះស្រាយបញ្ហានេះ។

ខ) ក្មេងស្រីដែលជាគ្រិស្តបរិស័ទម្នាក់ ដែលជាគំរូដ៏ល្អ និងជាទីបន្ទាល់នៃសេចក្តីស្រឡាញ់របស់ព្រះគ្រិស្ត បានស្លាប់ដោយមិនបានព្រៀងទុកនៅក្នុងឧបទ្ទវហេតុមួយ។ ដោយសារតែការ

ស្លាប់របស់នាង បាននាំមនុស្សជាច្រើននៅក្នុងសហគមន៍មករកព្រះអម្ចាស់ យើងដឹងថាតាមរយៈព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ទ្រង់បានរៀបចំផែនការនេះឡើងសម្រាប់រឿងដ៏ល្អប្រសើរមួយ។

គ) ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះគម្ពីរ គឺជាមគ្គុទេសក៍មួយសម្រាប់បង្ហាញខ្ញុំអំពីរបៀបរស់នៅជីវិតដ៏ល្អ និង ប្រកបដោយផលផ្លែមួយ។

ឃ) ព្រះជាម្ចាស់ប្រទានប្រាជ្ញាដល់អ្នកដឹកនាំក្រុមជំនុំ ដើម្បីធ្វើការខាងឯវិញ្ញាណនៅក្នុងក្រុមជំនុំដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។

ង) ការរៀបចំប្រមូលផ្តុំសិរីរាង្គកាយរបស់មនុស្ស បង្ហាញឲ្យឃើញពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។

ច) ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ មិនអនុញ្ញាតឲ្យគ្រិស្តបរិស័ទធ្វើខុសនៅក្នុងការវិនិច្ឆ័យទោសឡើយ។

១៩ ដើម្បីរំឭកផ្នែកនេះឡើងវិញ ចូរផ្គូផ្គងគុណលក្ខណៈបួនយ៉ាងរបស់ព្រះជាម្ចាស់ ទៅនឹងនិយមន័យនៃគុណលក្ខណៈនីមួយៗ។

| | | | |
|---|---|---|---|
| ........ក) | គុណសម្បត្តិមួយរបស់ព្រះជាម្ចាស់ដែលទ្រង់អាចមានវត្តមាននៅក្នុងគ្រប់ទីកន្លែង។ | ១) | សព្វានុភាព |
| .......ខ) | របៀបដែលព្រះជាម្ចាស់ធ្វើការដើម្បីផ្តល់គោលបំណងដ៏ខ្ពង់ខ្ពស់ តាមមធ្យោបាយដ៏ល្អបំផុត សម្រាប់ភាវៈរស់ដែលទ្រង់បានបង្កើត និង ស្នាព្រះហស្តទាំងអស់របស់ទ្រង់។ | ២) | សព្វញ្ញុណញាណ |
| .......គ) | គុណសម្បត្តិរបស់ព្រះជាម្ចាស់ដែលទ្រង់ជ្រាបដឹងរឿងគ្រប់យ៉ាង។ | ៣) | សព្វត្ថិភាព |
| .......ឃ) | គុណសម្បត្តិរបស់ព្រះជាម្ចាស់ដែលទ្រង់មានគ្រប់ឫទ្ធានុភាពទាំងអស់។ | ៤) | ព្រះប្រាជ្ញាញាណ |

នៅក្នុងមេរៀននេះ យើងបានពិភាក្សាអំពីនិស្ស័យរបស់ព្រះជាម្ចាស់ និង គុណលក្ខណៈធម្មជាតិរបស់ទ្រង់។ នៅក្នុងមេរៀនបន្ទាប់ យើងនឹងសិក្សាអំពីលក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់ និង កិច្ចការដែលប្រកបដោយព្រះចេស្តារបស់ទ្រង់។ ការនេះនឹងត្រៀមយើង ដើម្បីសិក្សាអំពីព្រះជាម្ចាស់ព្រះរាជបុត្រ និង ព្រះជាម្ចាស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅពេលដែលអ្នកបានយល់ដឹងកាន់តែច្រើនឡើង អំពីព្រះអាទិកររបស់យើង និង ទំនាក់ទំនងរបស់អ្នកជាមួយទ្រង់ អ្នកនឹងអាចបម្រើទ្រង់កាន់តែល្អប្រសើរ ព្រមទាំងធ្វើជាសក្ខីភាពទៅកាន់អ្នកដទៃ អំពីសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់។

# *ការប្រឡងផ្ទាល់ខ្លួន*

សំណួរពហុជម្រើស។ ចូរជ្រើសរើសចម្លើយមួយដែលល្អបំផុតសម្រាប់ប្រយោគនីមួយៗ។

១ គ្រិស្តបរិស័ទថ្វាយបង្គំតាមរបៀបរបស់ពួកគេ ដោយមិនថ្វាយបង្គំទីកន្លែងណាមួយ តាមទម្រង់ណាមួយ ឬ ការកំណត់ណាមួយនោះទេ ព្រោះព្រះជាម្ចាស់គឺជា

ក) វិញ្ញាណ

ខ) ការរួបរួម

គ) សព្វានុភាព

ឃ) ភាពអស់កល្បជានិច្ច

២ ប្រសិនបើខ្ញុំដឹងថាព្រះជាម្ចាស់ត្រាស់ដឹងគ្រប់ការ មានឫទ្ធានុភាពគ្រប់ទាំងអស់ និង គង់នៅគ្រប់ទីកន្លែង ខ្ញុំនឹង

ក) រស់នៅក្នុងជីវិតមួយដែលជាទីសព្វព្រះហឫទ័យសម្រាប់ព្រះជាម្ចាស់ និង ទុកចិត្តទ្រង់ថាជួយខ្ញុំនៅក្នុងគ្រប់បញ្ហាគ្រប់បែបយ៉ាងដែលខ្ញុំប្រឈមមុខ។

ខ) ដឹងថា ទោះបីខ្ញុំធ្វើជ្រើសរើសបែបណា ជម្រើសទាំងនោះគឺជាជម្រើសដែលព្រះជាម្ចាស់ជ្រើសរើសម្រាប់ខ្ញុំ ហើយគ្មានអ្វីដែលខ្ញុំអាចធ្វើបានដើម្បីផ្លាស់ប្តូរវានៅក្នុងជីវិតរបស់ខ្ញុំបានទេ។

គ) ដោះស្រាយបញ្ហា និង តម្រូវការប្រចាំថ្ងៃរបស់ខ្ញុំ តាមរបៀបផ្ទាល់ខ្លួនរបស់ខ្ញុំ ព្រោះខ្ញុំគួរតែយាងព្រះជាម្ចាស់មកក្នុងជីវិតរបស់ខ្ញុំ តែនៅពេលណាដែលមានបញ្ហាធំៗប៉ុណ្ណោះ។

៣ ដោយនិស្ស័យ និង គុណលក្ខណៈរបស់ព្រះជាម្ចាស់ ទ្រង់មិនត្រឹមតែមានសមត្ថភាពដឹងអ្វីដែលយើងត្រូវការប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏

ក) គង់នៅឆ្ងាយ មិនអាចយាងមកដោះស្រាយបញ្ហានោះបានទេ។

ខ) ជ្រាបថា ដោយសារយើងគ្មាននិស្ស័យ និង គុណលក្ខណៈដូចជាទ្រង់ ទ្រង់មិនអាចទាក់ទងជាមួយយើងឲ្យបានប្រកបអត្ថន័យជ្រាលជ្រៅនោះទេ។

គ) អាចប្រទានឲ្យយើងនូវគ្រប់តម្រូវការដែលយើងមានផងដែរ។

៤ នៅពេលដែលយើងដឹងថា ព្រះជាម្ចាស់ធ្វើការគ្រប់យ៉ាងដើម្បីផលល្អរបស់យើង និង សិរីរុងរឿងរបស់ទ្រង់ យើងនឹងមើលឃើញពី

ក) បុគ្គលិកលក្ខណៈរបស់ទ្រង់

ខ) ភាពអស់កល្បជានិច្ចរបស់ទ្រង់

គ) ព្រះប្រាជ្ញាញាណរបស់ទ្រង់

ឃ) សព្វញ្ញុតញាណរបស់ទ្រង់

**ត្រូវ- ខុស។** ចូរសរសេរអក្សរ ត នៅពីមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ នៅពីមុខប្រយោគដែលមិនត្រឹមត្រូវ។

........៥ គុណសម្បត្តិមួយរបស់ព្រះជាម្ចាស់ដែលបង្ហាញថា យើងអាចចូលទៅរកទ្រង់បាន និង ដែលថាទ្រង់ខ្វល់ព្រះហឫទ័យអំពីតម្រូវការជាមនុស្សរបស់យើង គឺភាពរួបរួម។

.........៦ ភាពជាគ្រិស្តបរិស័ទ គឺខុសពីការថ្វាយបង្គំព្រះជាច្រើន ព្រោះព្រះជាម្ចាស់នៅខាងឯវិញ្ញាណ។

.........៧ ព្រះគម្ពីរបង្រៀនយើងថា មានព្រះបីអង្គនៅក្នុងសមាសភាពរបស់ព្រះជាម្ចាស់៖ ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងអាចហៅគុណសម្បត្តិនេះថា ភាពរួបរួមរបស់ព្រះជាម្ចាស់។

.........៨ គុណសម្បត្តិរបស់ព្រះជាម្ចាស់ដែលរៀបរាប់ពី អត្ថិភាពរបស់ទ្រង់ដែលគ្មានទីចាប់ផ្តើម ឬ ទីបញ្ចប់ និង គុណសម្បត្តិដែលមិនប្រែប្រួលរបស់ទ្រង់ គឺភាពអស់កល្បជានិច្ច និង ភាពខ្ជាប់ខ្ជួនរបស់ទ្រង់។

.........៩ មនុស្សដែលមិនអាចមើលគោលបំណងនៅក្នុងបញ្ហានៅក្នុងជីវិតរបស់ពួកគេ ប្រហែលជាមិនអាចស្គាល់ច្បាស់ពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់បានទេ។

.........១០ ភស្តុតាងនៃគោលលិទ្ធអំពីព្រះត្រៃឯកជាច្រើន ត្រូវបានគេឃើញមាននៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់។

# ចម្លើយសម្រាប់សំណួរអនុវត្តន៍

១១ ក) និង ខ) ជាចម្លើយត្រឹមត្រូវ។

១ ចម្លើយរបស់អ្នក

១២ ក) ព្រះជាម្ចាស់ ; ពិភពលោក

ខ) បំណងព្រះហឫទ័យ ; ព្រះបន្ទូល

គ) វិនាស

ឃ) សេចក្ដីស្រឡាញ់ ; ភាពសុចរិត

២ ចម្លើយរបស់អ្នក។ ខ្ញុំបានសំគាល់ឃើញថាយើងស្គាល់អ្នកដទៃ តាមរយៈការនិយាយទៅកាន់ពួកគេ ស្ដាប់ពួកគេ និង សិក្សាអំពីពួកគេ។ ដើម្បីស្គាល់ព្រះជាម្ចាស់ យើងត្រូវចំណាយពេលវេលាដើម្បីធ្វើរឿងទាំងអស់នេះដូចគ្នា។

១៣ ក) ៣) ភាពរួបរួម

ខ) ៥) ភាពអស់កល្បជានិច្ច

គ) ២) ភាពជាវិញ្ញាណ

ឃ) ៤) ព្រះត្រៃឯក

ង) ៦) ភាពខ្វាប់ខ្ជួន

ច) ១) បុគ្គលិកលក្ខណៈ

៣ ខ) សមត្ថភាពក្នុងការធ្វើព្រះតម្រិះ ទទួលអារម្មណ៍ និង ធ្វើការសម្រេចព្រះទ័យរបស់ទ្រង់។

១៤ យើងនៅជាមួយអ្នកហើយ

៤ ខ) ព្រះជាម្ចាស់ជ្រាប និង យកព្រះទ័យទុកដាក់ ចំពោះតម្រូវការយុត្តិធម៌ ហើយទ្រង់ជ្រាប និង យកព្រះទ័យទុកដាក់នឹងភាពមានបាបរបស់អ្នកដែលធ្វើអំពើអាក្រក់។ ការទាំងនេះបង្ហាញឡើងតាមរបៀបនិមិត្តរូប។

១៥ យើងដឹងថាព្រះជាម្ចាស់តែងតែគង់នៅ ដើម្បីផ្ដល់កម្លាំង និង លើកទឹកចិត្តយើងនៅក្នុងពេលមានបញ្ហា។ យើងដឹងថាទ្រង់ទតឃើញអ្វីៗគ្រប់យ៉ាងដែលយើងធ្វើ មិនថាល្អឬអាក្រក់ក៏ដោយ ហើយយើងមានទំនួលខុសត្រូវក្នុងការបម្រើទ្រង់គ្រប់ពេលវេលា។

៥ ឃ) ចម្លើយ ក) , ខ) និង គ) ជាចម្លើយត្រឹមត្រូវ។

១៦ ក) ខទី១ដល់ទី៦......

ខ) ខទី១៣ដល់ទី១៩......

គ) ខទី៧ដល់ទី១២....

៦ ក) យើងជាព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត។
ខ) ព្រះអម្ចាស់ជាព្រះរបស់អ្នក ; កុំគោរពព្រះណាផ្សេង ក្រៅពីយើងឡើយ
គ) ឲ្យមានព្រះណាទៀតនៅជាមួយនឹងអញ(ពគប១៩៥៤)។
ឃ) ព្រះអម្ចាស់នៃយើងគឺជាព្រះជាម្ចាស់តែមួយគត់ ហើយក្រៅពីទ្រង់ គ្មានព្រះណាផ្សេងទៀតឡើយ។

៧ ប្រាកដណាស់ ផ្ទុត់គំនិតទាំងនេះគឺមានទាក់ទងគ្នា នៅពេលណាដែលរៀបរាប់អំពីភាពតែមួយ ឬ ភាពរួបរួមរបស់ព្រះជាម្ចាស់។ យើងបានផ្គូផ្គងគំនិតទាំងនេះតាមរបៀបដូចតទៅនេះ៖
ក) ២) ភាពពិសេសតែមួយ
ខ) ១) ភាពរួបរួមខាងឯចំនួន
គ) ២) ភាពពិសេសតែមួយ
ឃ) ៣) ភាពសាមញ្ញ
ង) ៣) ភាពសាមញ្ញ
ច) ៣) ភាពសាមញ្ញ
ឆ) ១) ភាពរួបរួមខាងឯចំនួន ឬ ២) ភាពពិសេសតែមួយ

១៧ ចម្លើយខ) ឃ) និង ង) ជាចម្លើយត្រឹមត្រូវ។

៨ ក) ព្រះជាម្ចាស់ព្រះវរបិតា
ខ) ព្រះជាម្ចាស់
គ) ព្រះជាម្ចាស់
ឃ) អង្គព្រះបីដោយឡែកពីគ្នា (ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ)។

១៨ ចម្លើយ ក) គ) ឃ) និង ង) ជាឧទាហរណ៍ដ៏ល្អអំពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។ ចម្លើយ ខ) គឺមិនមែនជាឧទាហរណ៍ដ៏ល្អនោះទេ ព្រោះឧបទ្ទវហេតុរបស់ក្មេងស្រីនោះ គឺជាលទ្ធផលដែលមកពីកំហុសរបស់មនុស្ស ហើយមិនមែនព្រះជាម្ចាស់ធ្វើឲ្យកើតឡើងនោះទេ។ ប៉ុន្តែ ព្រះជាម្ចាស់បានធ្វើការសម្រាប់ការល្អនៅក្នុងស្ថានភាពនោះដោយប្រើប្រាស់ស្ថានភាពនោះដើម្បីនាំមនុស្សឲ្យចូលមកឯទ្រង់ ហើយតាមរយៈការនេះ គេបានឃើញពីព្រះប្រាជ្ញាញាណរបស់ទ្រង់។ ចម្លើយ ច) ក៏មិនមែនជាឧទាហរណ៍ដ៏ល្អមួយដែរ ព្រោះតាមរយៈព្រះប្រាជ្ញាញាណ

ព្រះជាម្ចាស់អនុញ្ញាតឲ្យយើងធ្វើការសម្រេចចិត្តដោយខ្លួនឯង។ យើងអាចជ្រើសរើសយក ការទូលសូមទ្រង់ នូវប្រាជ្ញាក្នុងការធ្វើការសម្រេចចិត្ត។

៩ ក) ៥) ពហុភាពនៃអង្គព្រះ
ខ) ៣) ព្រះសង្គ្រោះ និង ព្រះវិញ្ញាណដ៏វិសុទ្ធ
គ) ២) ព្រះប្រោសលោះ ឬ ព្រះសង្គ្រោះ
ឃ) ១) ព្រះវិញ្ញាណដ៏វិសុទ្ធ
ង) ៤) អង្គព្រះនៅក្នុងព្រះត្រៃឯក

១៩ ក) ៣) សព្វត្ថិភាព

ខ) ៤) ព្រះប្រាជ្ញាញាណ

គ) ២) សព្វញ្ញុណញាណ

ឃ) ១) សព្វានុភាព

១០ ចម្លើយ ក) ខ) ឃ) ង) និង ច) ជាចម្លើយត្រឹមត្រូវ។